00712876

**Declassified to Public**
**28 October 2021**

ឯកសារទទួល លេខ/No: D20/4/1
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 07 / 07 / 2011
ម៉ោង (Time/Heure) : 15:55
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**<u>ព័ត៌មានពិស្តារនៃការដាក់ឯកសារ</u>**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | 00៣/0៧-0៩-២00៩-អវតក/កសចស (អបជ ០៤) |
| **ដាក់ទៅ** | : | អង្គបុរេជំនុំជម្រះ |
| **ថ្ងៃដាក់** | : | ថ្ងៃទី0៧ ខែកក្កដា ឆ្នាំ២0១១ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| **ភាសាដើម** | : | **អង់គ្លេស** |

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សម្ងាត់**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយ~~ការិយាល័យសហចៅក្រមស៊ើបអង្កេត~~:(អបជ)សម្ងាត់ / Confidential / Confidentiel

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ជំទាស់នឹង**
**"សេចក្តីសម្រេចស្តីពីសំណើសុំពន្យារពេលកំណត់ និងសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ**
**ស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងសំណុំរឿង 00៣"**

---

**<u>អ្នកដាក់ឯកសារ:</u>**
**សហព្រះរាជអាជ្ញាអន្តរជាតិ:**
លោក Andrew CAYLEY

**<u>អ្នកទទួលឯកសារ:</u>**
**អង្គបុរេជំនុំជម្រះ:**
ចៅក្រម ប្រាក់ គឹមសាន
ចៅក្រម Rowan DOWNING
ចៅក្រម ន័យ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
លោក ពេជ អង្គ
Elisabeth SIMMONEAU FORT

**<u>ចម្លងជូន:</u>**
**សហព្រះរាជអាជ្ញាជាតិ:**
លោកស្រី ជា លាង

# មាតិកា

**១. សេចក្ដីផ្ដើម**......................................................................................................................................៣
**២. ប្រវត្តិនីតិវិធី**........................................................................................................................................៤
**៣. និដ្ឋភាពទូទៅនៃបណ្ដឹងឧទ្ធរណ៍**................................................................................................................៧
**៤. អំពីច្បាប់ជាធរមាន**.............................................................................................................................៩
**៥. អំណះអំណាង**......................................................................................................................................១១
**៥(ក). ដីកាដែលកំពុងតវ៉ាមានមូលដ្ឋាននៅលើការបកស្រាយច្បាប់មិនត្រឹមត្រូវ**....................១១
*(១) សេចក្ដីសម្រេចដើម្បី ផ្ទេរអំណាច ឬ ធ្វើកំណត់ហេតុស្ដីពីការខ្វែងយោបល់គ្នា គឺ តាមជម្រើស មិនមែន ដាច់ខាតទេ*.....................................................................១១
*(២) ការអនុវត្តន៍ក្នុងការដាក់ឯកសារតែម្នាក់ឯង កាលពីមុនមក ធ្លាប់ត្រូវបាន យល់ព្រមដោយ សចស*..................................................................................................១២
*(៣) ការបកស្រាយរបស់សហចៅក្រមស៊ើបអង្កេត គឺមិនស្របគ្នាទៅ នឹងកម្មវត្ថុនិងគោលបំណងនៃច្បាប់ជាធរមានឡើយ*....................................................១៥
**៥(ខ). សំណើទាំងបួន មានការទាក់ទងដោយផ្ទាល់ទៅនឹងការខ្វែងយោបល់គ្នា ដែលធំជាងនេះ នៅក្នុងសំណុំរឿងលេខ០០៣**.........................................................................១៧
**៥(គ). តាមរបៀបផ្សេង បើសិនជាអង្គបុរេជំនុំជម្រះពិចារណាអំពីការផ្ទេរអំណាច ឬធ្វើកំណត់ហេតុចំពោះការខ្វែងយោបល់គ្នា ថាកាតព្វកិច្ចត្រូវដាក់ដោយ មិនចំណុះគ្នាក៏ដោយក៏ សចស មានការភាន់ច្រឡំនៅក្នុងការបដិសេធលើ សំណើសុំដែរ**...........................................................................................................១៩
*(១) សចស បានខកខានក្នុងការគិតគូរអំពីគោលការណ៍ជាមូលដ្ឋាន នៃវិធាន២១*........................................................................................................................១៩
*(២) ការខកខានរបស់ សចស មិនបានពិចារណាលើសំណើ គឺជាការបំពាននឹង កាតព្វកិច្ចតាមផ្លូវច្បាប់របស់ សចស ដែលត្រូវដឹកនាំបំពេញកិច្ចស៊ើបសួរឲ្យបាន ចប់សព្វគ្រប់ និង មិនលំអៀង*.............................................................................................២៧
**៦. សេចក្ដីសន្និដ្ឋាន**.................................................................................................................................៣០

## ១. សេចក្ដីផ្ដើម

១. ដោយអនុលោមតាមវិធាន ៦៦.២, ៦៦.៣, ៧៤.២, ៧៥.៣ និង ២១ នៃវិធានផ្ទៃក្នុង (“វិធាន”) សហព្រះរាជអាជ្ញាអន្តរជាតិ សូមដាក់ជូននូវបណ្ដឹងឧទ្ធរណ៍នេះជំទាស់នឹងដីកាសម្រេចដោយមានសំអាងហេតុ[1] របស់សហចៅក្រមស៊ើបអង្កេត(“សចស”) ដែលមានចំណងជើងថា “ដីកាសម្រេចស្ដីពីសំណើសុំពន្យារពេលកំណត់ និងសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ ស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងសំណុំរឿង ០០៣” (“ដីកាដែលកំពុងតវ៉ា”)[2] ។

២. បណ្ដឹងឧទ្ធរណ៍នេះគឺអាចទទួលយកបាន ។ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់សេចក្ដីជូនដំណឹងស្ដីពីការប្ដឹងឧទ្ធរណ៍នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១១ (ត្រូវបានជូនដំណឹង នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១១) ហើយបណ្ដឹងឧទ្ធរណ៍នេះ ដែលដាក់នៅថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ២០១១ គឺវាត្រូវទៅតាមកាលបរិច្ឆេទកំណត់ដែលបានចែងនៅក្នុងអនុវិធាន ៧៥.១ និង ៧៥.៣ ។ សហព្រះរាជអាជ្ញាអន្តរជាតិ សន្និដ្ឋានថា គាត់មានសិទ្ធិដាក់បណ្ដឹងឧទ្ធរណ៍នេះតែម្នាក់ឯងបាន ដោយពុំចាំបាច់មានការផ្ទេរអំណាច អនុលោមតាមវិធាន ១៣.៣ ឬ ធ្វើកំណត់ហេតុស្ដីពីការខ្វែងយោបល់ អនុលោមតាមវិធាន ៧១.១ នោះទេ[3] ។ ថ្វីបើគោលជំហរនេះ និងក្រៅពីភាពសម្បូរណ៍ការប្រុងប្រយ័ត្ននៅមុនពេលដាក់បណ្ដឹងឧទ្ធរណ៍នេះក៏ដោយ ក៏ការខ្វែងយោបល់គ្នាមួយត្រូវបានធ្វើកំណត់ហេតុ ទៅតាមការផ្ដួចផ្ដើមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ នៅក្នុងឯកសារមួយដោយមានចុះហត្ថលេខា និងកាលបរិច្ឆេទ ដាក់ចូលទៅក្នុងសំណុំឯកសារនៃការខ្វែងយោបល់គ្នា ដែលរក្សាទុកដោយក្រឡាបញ្ជីរបស់សហព្រះរាជអាជ្ញា ។

[1] ទោះបីជា ដីកាដែលកំពុងតវ៉ា មានដាក់ចំណងជើងថា “ដីកាសម្រេច” ក៏ដោយក៏គេមិនមានចម្ងល់ទេថា នៅក្នុងវិធានផ្ទៃក្នុង ពាក្យថា “ដីកាសម្រេច” ឬ “ដីកាបង្គាប់” ដែលសហចៅក្រមស៊ើបអង្កេតបានប្រើប្រាស់នោះ គឺអាចផ្លាស់ប្ដូរគ្នាទៅវិញទៅមកបាន៖ អនុវិធាន៦៦.២ និង ៦៦.៣ បានចែងថា “នៅពេលដែលសហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធសំណើបែបទាំងនេះ សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាបដិសេធដោយមានសំអាងហេតុ” និង “ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ ក្រោយពីបានទទួលដំណឹងអំពីដីកាសម្រេចនេះ ភាគីទាំងអស់អាចប្ដឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ” ។ វិធាន ៧៤.១ ប្រើពាក្យ “សេចក្ដីសម្រេច” រីឯវិធាន ៧៤.២ និង ៧៤.៤ ប្រើពាក្យ “ដីកា” ។ វិធាន ៧៤.៣ និង ៧៥ ជាភាសាអង់គ្លេស ប្រើពាក្យ “ដីកា” និង “សេចក្ដីសម្រេច”, រីឯវិធាន ៧៥ ជាភាសាបារាំង ប្រើតែពាក្យ “សេចក្ដីសម្រេច” ប៉ុណ្ណោះ ។ លើសពីនេះទៀត វចនានុក្រមច្បាប់ពណ៌ខ្មៅ (Black’s Law Dictionary) បានឲ្យនិយមន័យទៅលើពាក្យ “សេចក្ដីសម្រេច” ថាជាសទិសន័យស័ព្ទជាមួយនឹងពាក្យ “ដីកា” (វចនានុក្រមច្បាប់ពណ៌ខ្មៅ, បោះពុម្ពលើកទី៨, Garner, B, ទំព័រទី ៤៣៦) ។

[2] ដីកាសម្រេចស្ដីពីសំណើសុំពន្យារពេលកំណត់ និងសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងសំណុំរឿង ០០៣, ថ្ងៃទី៧ មិថុនា ២០១១, D20/3, (បន្ទាប់ពីនេះទៅហៅថា “ដីកាដែលកំពុងតវ៉ា”) ។

[3] ជាការបន្ថែមទៅនឹងអំណះអំណាងនានាដែលបានលើកឡើងនៅក្នុងសំណើនេះ នៅមានអំណះអំណាងផ្សេងៗទៀតដែលបានលើកឡើង នៅក្នុងបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹង “ដីកាសម្រេចស្ដីអំពីសេចក្ដីប្រកាសព័ត៌មានជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងសំណុំរឿង ០០៣”, D14/1/1, ថ្ងៃទី២៥ ឧសភា ២០១១, កថាខណ្ឌទី ១២-១៣ ដែលទាក់ទងដោយផ្ទាល់ទៅនឹងសិទ្ធិអំណាចរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងការដាក់បណ្ដឹងឧទ្ធរណ៍តែម្នាក់ឯង ។

## ២. ប្រវត្តិនីតិវិធី

៣. នៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី បានដាក់ជូន សចស នូវដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីពីរ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ") សុំឱ្យបើកការស៊ើបសួរនៅក្នុងករណីនេះ[4] ។ សចស បានដាក់ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះចូលទៅក្នុងសំណុំរឿងនៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០១០ ។ នៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ(នាពេលនោះ) បានចេញដីកាចាត់ឱ្យស៊ើបសួរជំនួសមួយ ដោយបង្គាប់ឱ្យអ្នកស៊ើបអង្កេតនានានៃការិយាល័យសហចៅក្រមស៊ើបអង្កេត ("កសចស") ចុះទៅធ្វើការស៊ើបសួរដល់ទីកន្លែង ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍/ទីកន្លែងឧក្រិដ្ឋកម្ម ចំនួន០៧(ប្រាំពីរ)កន្លែង ដែលបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[5] ។ ជាលទ្ធផលនៃការស៊ើបសួរដល់ទីកន្លែងទាំងនេះ មានកំណត់ហេតុស្តាប់ចម្លើយសាក្សីសរុបចំនួន១៧(ដប់ប្រាំពីរ) និងរបាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងចំនួន០៥(ប្រាំ) ត្រូវបានដាក់ចូលទៅក្នុងសំណុំរឿង[6] ។ ស.ច.ស បច្ចុប្បន្ន ត្រូវបានគេចាត់តាំង និងចូលធ្វើការនៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១១[7] ។

៤. ចាប់តាំងពីខែធ្នូ ឆ្នាំ២០១១ មានការស្តាប់ចម្លើយចំនួន០៣(បី) ត្រូវបាន សចស ដឹកនាំធ្វើដោយខ្លួនឯង នៅថ្ងៃទី២៤ ខែមីនា, ថ្ងៃទី២៥ ខែមីនា និង ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១១[8] ។ ឯកសារជាច្បាប់ចម្លងជាង ១,២០០ នៃសំណុំរឿងលេខ ០០១ និងសំណុំរឿងលេខ ០០២ ត្រូវបានដាក់ចូលទៅក្នុងសំណុំរឿងលេខ ០០៣[9] ។ គ្មានភស្តុតាងណាមួយក្នុងចំណោមភស្តុតាងខាងលើ

---

[4] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីអំពីការដាក់ឯកសារស្តីពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីពីរ, ថ្ងៃទី០៧ កញ្ញា ២០០៩, D1/1 ។

[5] ដីកាចាត់ឱ្យស៊ើបសួរជំនួស, ថ្ងៃទី០៩ មិថុនា ២០១០, D2 ។

[6] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី៖ ប៊ិាន រុំ, ថ្ងៃទី២៤ សីហា ២០១០, D2/5 ។ អ៊ុំ កែវ, ថ្ងៃទី២៨ កញ្ញា ២០១០, D2/11 ។ ម៉ៅ ផាត, ថ្ងៃទី២៩ កញ្ញា ២០០១, D2/12 ។ សាយ តាយ, ថ្ងៃទី២៥ កញ្ញា ២០១០, D2/13 ។ ម៉ាង បូលីន, ថ្ងៃទី២៦ កញ្ញា ២០១០, D2/14 ។ ប៉ូច កុយ, ថ្ងៃទី២៨ កក្កដា ២០១០, D2/4 ។ ញូង ជ្រោង, ថ្ងៃទី២៤ សីហា ២០១០, D2/6 ។ ប៉ែន សារិន, ថ្ងៃទី២៦ សីហា ២០១០, D2/7 ។ សយ ប៊ន, ថ្ងៃទី៦, ៧, និង ៩ កញ្ញា ២០១០, (D2/8, D2/9, D2/10) ។ ទូច សៀលី, ថ្ងៃទី១០ និង ១១ វិច្ឆិកា ២០១០, (D2/15, D2/16) ។ អ៊ិន សារឿន, ថ្ងៃទី១២ វិច្ឆិកា ២០១០, D2/17 ។ អ៊ូ លាង, ថ្ងៃទី១៣ កក្កដា ២០១០, D2/2 ។ ណុប ហាត *ហៅ* លី ហាត *ហៅ* ណុប ហុន, ថ្ងៃទី២០ កក្កដា ២០១០, D2/3 និង ស្រេង ធី, ថ្ងៃទី០១ ធ្នូ ២០១០, D2/18 ។ របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង៖ ថ្ងៃទី០៤ វិច្ឆិកា ២០១០, D2/19 ។ ថ្ងៃទី០៤ វិច្ឆិកា ២០១០, D2/20 ។ ថ្ងៃទី០៩ ធ្នូ ២០១០, D2/21 ។ ថ្ងៃទី៣០ ធ្នូ ២០១០, D2/23 និងថ្ងៃទី ២៩ ធ្នូ ២០១០, D2/22 ។

[7] សេចក្តីប្រកាសព័ត៌មាន - បណ្ឌិត Siegfried Blunk ត្រូវបានចាត់តាំងជា សហចៅក្រមស៊ើបអង្កេតអន្តរជាតិថ្មី, ថ្ងៃទី០១ ធ្នូ ២០១០ (ឧបសម្ព័ន្ធទី ១) ។

[8] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី៖ ឈូក រិន, ថ្ងៃទី២៤ មីនា ២០១១, D6 ។ សំ ប៊ុនឡេង, ថ្ងៃទី២៥ មីនា ២០១១, D8 ។ កាំង ហ្កេកអ៊ាវ *ហៅ*ឌុច ថ្ងៃទី២៧ មេសា ២០១១, D12 ។

[9] សេចក្តីជូនដំណឹងស្តីពីការដាក់ឯកសារចូលទៅក្នុងសំណុំរឿងលេខ ០០៣, ថ្ងៃទី៥ មេសា ២០១១, D4 ។ សេចក្តីជូនដំណឹងស្តីពីការដាក់ឯកសារចូលទៅក្នុងសំណុំរឿងលេខ ០០៣, ថ្ងៃទី២៥ មេសា ២០១១, D10 ។

ត្រូវបានដាក់ចូលទៅក្នុងសំណុំរឿងលេខ០០៣ ទេ រហូតដល់ខែមីនា ឆ្នាំ២០១១ ។ នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ សចស បានជូនដំណឹងដល់សហព្រះ រាជអាជ្ញានូវសេចក្តីជូនដំណឹងស្តីពីការបិទការស៊ើបសួរ[10] ។ បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងនេះ សហព្រះរាជអាជ្ញាអន្តរជាតិក៏បានធ្វើការពិនិត្យដ៏ប្រញាប់លើសំណុំរឿងនោះ ដោយយោងទៅតាមកាតព្វកិច្ចរបស់ខ្លួននៅក្នុងវិធាន ៦៦.៥ ។ គាត់បានធ្វើការសន្និដ្ឋានបញ្ចប់ថា ការស៊ើបសួរនេះនៅមិនទាន់បានបំពេញចប់សព្វគ្រប់នៅឡើយទេ ។ គាត់ក៏បានធ្វើការកត់សម្គាល់ផងដែរថា សំណុំរឿងលេខ ០០៣ មានពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតែ០២(ពីរ)ប៉ុណ្ណោះ បើទោះបីជាអង្គហេតុថាមានទីតាំងឧក្រិដ្ឋកម្ម និងព្រឹត្តិការណ៍ឧក្រិដ្ឋជាច្រើនដែលឋិតនៅក្រោមកិច្ចស៊ើបសួរនេះក៏ដោយ ។ ជាការឆ្លើយតបទៅនឹងសេចក្តីជូនដំណឹងនេះ សហព្រះរាជអាជ្ញាអន្តរជាតិបានចេញសេចក្តីប្រកាសព័ត៌មានមួយ នៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១១[11] ។ នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១១ បានដាក់សំណើសុំពន្យារពេលក្នុងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[12] និងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរចំនួន០៣(បី) អនុលោមតាមវិធាន ៦៦.១ (ទាំងនេះជាមួយគ្នា "សំណើ") នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១[13] ។ សំណើសុំទាំងនេះ រួមមានទាំងឧបសម្ពន្ធចំនួន ០២(ពីរ) ផង ត្រូវផ្ទេរពីសំណុំរឿងលេខ ០០២ ចូលទៅ ក្នុងសំណុំរឿងលេខ ០០៣ ហើយនិងឯកសារថ្មីពាក់ព័ន្ធផ្សេងៗទៀត ។ សំណើទាំងនេះ ក៏មានចែងនូវកិច្ចស៊ើបសួរបន្ថែមទៀត ដើម្បីបង្ហាញការពិតដែលពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍/ទីតាំង ឧក្រិដ្ឋកម្មនានាដែលបានលើកឡើងចោទប្រកាន់ និងការទទួលខុសត្រូវរបស់ជនសង្ស័យនានា ។

៥. នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១១ សហព្រះរាជអាជ្ញា ត្រូវបានជូនដំណឹងដោយ ដីកាពាក់ព័ន្ធនឹងសំណើសុំពន្យារពេល និងបំពេញកិច្ចស៊ើបសួរនានារបស់សហព្រះរាជអាជ្ញាអន្តរជាតិ នៅក្នុង

[10] សេចក្តីជូនដំណឹងស្តីពីការបិទការស៊ើបសួរ, ថ្ងៃទី២៩ មេសា ២០១១, D13, ត្រង់ទំព័រទី ២ ។

[11] សេចក្តីប្រកាសប្រកាសព័ត៌មាន គឺជាប្រធានបទនៃដីកាសម្រេចរបស់ សចស ចុះថ្ងៃទី១៨ ឧសភា ២០១១ ("ដីកាសម្រេចឱ្យដក")៖ ដីកាសម្រេចស្តីពីការប្រកាសព័ត៌មានជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងសំណុំរឿង ០០៣, ថ្ងៃទី១៨ ឧសភា ២០១១, D14 ។ ដីកាសម្រេចឱ្យដក ត្រូវបានប្តឹងឧទ្ធរណ៍ដោយសហព្រះរាជអាជ្ញាអន្តរជាតិនៅថ្ងៃទី២៥ ឧសភា ២០១១, (D14/1/1), បន្ទាប់មកអង្គបុរេជំនុំជម្រះ បានចេញ ដីកាសម្រេចព្យួរការអនុវត្តលើ "ដីកាសម្រេចស្តីពីសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងសំណុំរឿង ០០៣", ថ្ងៃទី១៣ មិថុនា ២០១១, D14/1/2 ។

[12] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំពន្យារពេលវេលាកំណត់សម្រាប់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី, ថ្ងៃទី១០ ឧសភា ២០១១, D15 ("សំណើសុំពន្យារពេលវេលាកំណត់") ។

[13] សំណើបំពេញកិច្ចស៊ើបសួរលើកទីមួយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យទទួលយកឯកសារបន្ថែម និងសេចក្តីសង្កេតលើស្ថានភាពនៃកិច្ចស៊ើបសួរ, ថ្ងៃទី១៨ ឧសភា ២០១១, D17 (ដោយមានភ្ជាប់នូវតារាងឯកសារចំនួនពីរ) ("សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ១") ។ សំណើលើកទី ២ របស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរបន្ថែម ពាក់ព័ន្ធនឹងលោក ស៊ូ មេត ព្រមទាំងពាក់ព័ន្ធនឹងទីកន្លែងប្រព្រឹត្តបទល្មើស, ថ្ងៃទី១៨ ឧសភា ២០១១, D18 ("សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ២") ។ សំណើបំពេញកិច្ចស៊ើបសួរលើកទីបីរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទិននឹង មាស មុត និងទីតាំងឧក្រិដ្ឋកម្មដែលពាក់ព័ន្ធ, ថ្ងៃទី១៨ ឧសភា ២០១១, D19 ("សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ៣") ។

សំណុំរឿង ០០៣ របស់ សចស ("ដីកាទីមួយ")[14] ។ តាមរយៈ ដីកាទីមួយនេះ សចស បានបង្គាប់ "សហព្រះរាជអាជ្ញាឱ្យធ្វើការបំភ្លឺក្នុងរយៈពេលពីរថ្ងៃនៃថ្ងៃធ្វើការ ថាតើមុនពេលដែលដាក់សំណើសុំពន្យារពេល និងសំណើសុំបំពេញកិច្ចស៊ើបសួរ ពួកគាត់បានធ្វើសេចក្តីសម្រេចមួយ [sic] អំពីការផ្ទេរអំណាច ស្របតាមវិធាន ១៣.៣ ឬ ពួកគាត់បានធ្វើកំណត់ហេតុស្តីពីការខ្វែងយោបល់គ្នា ស្របតាមវិធាន ៧១.១" ។ នៅក្នុងដីកាទីមួយនេះ សចស បានបញ្ជាក់អំពីការយល់ឃើញរបស់ខ្លួនក្នុងការទទួលបាននូវ "ការបញ្ជាក់ថា តើសហព្រះរាជអាជ្ញាជាតិត្រូវបានផ្តល់ឱកាសក្នុងការប្រើប្រាស់សិទ្ធិរបស់ខ្លួន ដែលមានចែងនៅក្នុងវិធាន ១៣.៣ និងវិធាន ៧១.១ ដែរឬទេ"[15] ។

៦. សហព្រះរាជអាជ្ញាជាតិ បានឆ្លើយតបនៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១១ ថាមិនមានធ្វើការផ្ទេរសិទ្ធិអំណាច ឬធ្វើកំណត់ហេតុនូវការខ្វែងយោបល់គ្នានេះទេ[16] ។ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ចម្លើយតបរបស់ខ្លួន នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១១ ("ចម្លើយតប")[17] ដោយបានអះអាងថា ទាំងការផ្ទេរសិទ្ធិអំណាច អនុលោមតាមវិធាន ១៣.៣ ឬ ទាំងការធ្វើកំណត់ហេតុមួយតាមទម្រង់ការស្តីពីការខ្វែងយោបល់គ្នា អនុលោមតាមវិធាន ៧១.១ នោះ គឺមិនមែនជាការចាំបាច់តាមផ្លូវច្បាប់ សម្រាប់ឱ្យសហព្រះរាជអាជ្ញាអន្តរជាតិដាក់សំណើនានាដែលជាសំណើឯករាជ អាចទទួលយកបាន នៅក្នុងសំណុំរឿងលេខ ០០៣ នោះឡើយ ។ ដោយឡែក សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា៖ ទី១) មានការអនុវត្តក្នុងការដាក់ឯកសារតែម្នាក់ឯងដែលធ្លាប់ត្រូវបានទទួលយក, ទី២) សហព្រះរាជអាជ្ញាជាតិ បានជ្រើសរើសមិនផ្ទេរសិទ្ធិអំណាច ឬធ្វើកំណត់ហេតុស្តីពីការខ្វែងយោបល់គ្នា, និងទី៣) ការខ្វែងយោបល់គ្នាដំបូងពាក់ព័ន្ធទៅនឹងការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ នៅក្នុងសំណុំរឿងលេខ០០៣ បានក្តោបទៅលើការបំពេញកិច្ចឯករាជជាបន្តបន្ទាប់នៅពេលក្រោយៗទៀតរបស់អយ្យការ នៅក្នុងបរិបទនៃសំណុំរឿងលេខ ០០៣ ។

៧. នៅថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១១ ដីកាដែលកំពុងតវ៉ា ត្រូវបានចេញដោយ សចស ។ ដីកាដែលកំពុងតវ៉ា មិនមានលើកឡើងនូវសំនួរ "ថាតើសហព្រះរាជអាជ្ញាជាតិត្រូវបានផ្តល់ឱកាសក្នុងការប្រើប្រាស់សិទ្ធិរបស់ខ្លួន ដែលមានចែងនៅក្នុងវិធាន ១៣.៣ និងវិធាន ៧១.១ ដែរឬទេ" ទោះបីជារឿងនេះត្រូវបានលើកឡើងយ៉ាងច្បាស់លាស់ថាជាយុត្តិកម្មមួយសម្រាប់ចេញដីកាទីមួយ ក៏ដោយ ។ ផ្ទុយទៅវិញ ដីកាដែលកំពុងតវ៉ានេះ គ្រាន់តែបានឆ្លើយតបទៅនឹងអំណះអំណាងចំនួន ០៣(បី) ខាង

[14] ដីកាពាក់ព័ន្ធនឹងសំណើសុំពន្យារពេល និងបំពេញកិច្ចស៊ើបសួរនានារបស់សហព្រះរាជអាជ្ញាអន្តរជាតិ នៅក្នុងសំណុំរឿង ០០៣, ថ្ងៃទី១៩ ឧសភា ២០១១ (ត្រូវបានជូនដំណឹង នៅថ្ងៃទី២៤ ឧសភា ២០១១), D20 ("ដីកាទីមួយ") ។

[15] ដីកាទីមួយ, ទំព័រទី២, "សេចក្តីពិចារណា" ទីពីរ ។

[16] ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិ ទៅនឹងដីកាពាក់ព័ន្ធទៅនឹងសំណើសុំពន្យារពេល និងបំពេញកិច្ចស៊ើបសួរនានារបស់សហព្រះរាជអាជ្ញាអន្តរជាតិ នៅក្នុងសំណុំរឿង ០០៣, ថ្ងៃទី២៥ ឧសភា ២០១១, D20/1 ។

[17] ចម្លើយតបរបស់សហព្រះរាជអាជ្ញា(អន្តរជាតិ) ចំពោះដីកាសម្រេចរបស់ សចស ស្តីពីសំណើសុំពន្យារពេលកំណត់ និងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យបំពេញកិច្ចស៊ើបសួរ នៅក្នុងសំណុំរឿង ០០៣, ថ្ងៃទី២៦ ឧសភា ២០១១, D20/2 ។

លើដែលបានដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិតែប៉ុណ្ណោះ[18] ។ សចស បានសន្និដ្ឋានថា វិធានផ្ទៃក្នុង មិនមានទុកចន្លោះប្រហោងសម្រាប់[ឱ្យបំពេញ]កិច្ចការតែម្នាក់ឯងនោះទេ ហើយដោយហេតុនេះ បានបដិសេធសំណើសុំទាំងនោះថាគ្មានសុពលភាព ដោយពុំបានធ្វើការវាយតម្លៃលើអង្គសេចក្តីរបស់សំណើទាំងនោះទេ ។ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់សេចក្តីជូនដំណឹងមួយស្តីពីការប្តឹងឧទ្ធរណ៍នៅថ្ងៃ ទី១០ ខែមិថុនា ឆ្នាំ២០១១ បន្ទាប់ពីមានធ្វើកំណត់ហេតុនៃការខ្វែងយោបល់គ្នា ជាមួយនឹង សហព្រះរាជអាជ្ញាជាតិ អនុលោមតាមវិធាន ៧១.១ ។

៨. ចាប់ពីពេលនោះមក នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ជូនម្តងទៀតនូវសំណៅដែលបានកែប្រែ លើសំណើសុំពន្យារពេលពីលើកដំបូង និងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរពីលើកដំបូង ។ គាត់បានធ្វើយ៉ាងដូច្នេះដោយផ្អែកលើមូលដ្ឋានមួយ ដែលថាតាមវិធាន ៣៩ នៃវិធានផ្ទៃក្នុង ក៏ដូចជាតាមមាត្រា ៨ និង ៩ នៃសេចក្តីណែនាំអនុវត្តក្នុងការដាក់ឯកសារនៅចំពោះមុខ អវតក ដូច្នោះដែរ សចស មានឆន្ទានុសិទ្ធិដើម្បីទទួលស្គាល់នូវសុពលភាពនៃសំណើយឺតយ៉ាវទាំងនោះ នៅពេលនេះ ដែលថាទម្រង់បែបបទនានាគឺជាការចាំបាច់ដោយ សចស ត្រូវបានបញ្ជាក់បំភ្លឺនៅក្នុង ដីកាដែលកំពុងតវ៉ា របស់ខ្លួន ។ លើសពីនេះទៀត ទោះបីជាសហព្រះរាជអាជ្ញាអន្តរជាតិ នៅតែមិនយល់ស្របទៅនឹងការបកស្រាយរបស់ សចស លើវិធានផ្ទៃក្នុង នៅឡើយយ៉ាងណាក៏ដោយ ក៏គាត់បានធ្វើដោយសុទ្ធចិត្តទៅតាមសេចក្តីសម្រេចរបស់ពួកគាត់ ហើយបានធ្វើកំណត់ហេតុស្តីពីការខ្វែងយោបល់គ្នាចំនួន ០៤(បួន) ។ សព្វថ្ងៃនេះ សចស មិនទាន់បានធ្វើសេចក្តីសម្រេចណាមួយពាក់ព័ន្ធទៅនឹងការទទួលយកបាននូវសំណើ ដែលបានដាក់ឡើងវិញទាំងនោះ នៅឡើយទេ ។

## ៣. និដ្ឋភាពទូទៅនៃបណ្តឹងឧទ្ធរណ៍

៩. សហព្រះរាជអាជ្ញាអន្តរជាតិ សូមជូនសេចក្តីសន្និដ្ឋានថា ដីកាដែលកំពុងតវ៉ានោះ គួរតែត្រូវបានបដិសេធចោល ដោយមានទទឡ្ហីករណ៍ទាំងឡាយដូចខាងក្រោមនេះ៖

ក. សចស បានខុសឆ្គងនៅក្នុងការបកស្រាយច្បាប់ជាធរមាន ខណៈដែលពួកគាត់បានពិចារណាថា លើសំណើនានា ដែលបានដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិតែម្នាក់ឯង គឺមិនមានសុពលភាពទេ មកពីអវត្តមាននៃការផ្ទេរអំណាច ទៅតាមវិធាន ១៣.៣ ឬ អវត្តមាននៃកំណត់ហេតុតាមទម្រង់ការមួយស្តីពីការខ្វែងយោបល់គ្នា ដោយសហព្រះរាជអាជ្ញាម្នាក់ ក្នុងចំណោមសហព្រះរាជអាជ្ញាទាំងពីរ ទៅតាមវិធាន ៧១.១ ។ ដោយឡែក៖

(i) យោងទៅតាមវិធាន ការផ្ទេរអំណាច ឬ ការធ្វើកំណត់ហេតុស្តីពីការខ្វែងយោបល់គ្នា គឺមិនមានលក្ខណៈដាច់ខាត(mandatory) ទេ ប៉ុន្តែផ្ទុយទៅវិញគឺមានលក្ខណៈតាមជម្រើស(optional) ។ លទ្ធភាពក្នុងការបំពេញកិច្ចការតែម្នាក់ឯងនៅក្នុងកាលៈទេសៈ

[18] ដីកាដែលកំពុងតវ៉ា, កថាខណ្ឌទី ៣, ៦, ៨-១១ ។

មួយចំនួនគឺត្រូវបានចែងយ៉ាងច្បាស់នៅក្នុងមាត្រា៤ នៃកិច្ចព្រមព្រៀង, មាត្រា២០(ថ្មី) នៃច្បាប់ អវតក, វិធាន ១.២, ១៣ និង ៧១ ។

(ii) ការអនុវត្តក្នុងការដាក់ឯកសារតែម្នាក់ឯង ពីមុនមកត្រូវបានទទួលយកដោយ សចស អន្តរជាតិ ក៏ដូចជា សចស ទាំងពីរនាក់ដែរ ។ ការណ៍នេះបានគាំទ្រដល់ការបកស្រាយវិធាន របស់សហព្រះរាជអាជ្ញាអន្តរជាតិ ដូចជាការប្រគល់ឱ្យសហព្រះរាជអាជ្ញានូវសិទ្ធិក្នុងការផ្ទេរអំណាច ឬក្នុងការធ្វើកំណត់ហេតុ គឺមិនមែនតម្រូវឱ្យពួកគាត់ធ្វើដូច្នេះនោះទេ ។

(iii) សហព្រះរាជអាជ្ញាជាតិ ត្រូវបានផ្តល់ឱកាសក្នុងការប្រើប្រាស់សិទ្ធិរបស់ខ្លួន នៅមុនពេលដែលសហព្រះរាជអាជ្ញាអន្តរជាតិជាតិបានដាក់សំណើនានា ហើយគាត់បានជ្រើសរើសយក ការមិនផ្ទេរសិទ្ធិអំណាចរបស់គាត់ ឬ ការមិនធ្វើកំណត់ហេតុស្តីពីការខ្វែងយោបល់គ្នា ។ យ៉ាងណាក៏ដោយ ការបកស្រាយរបស់ សចស លើវិធានថាតម្រូវឱ្យមានការផ្ទេរអំណាច ឬ ការធ្វើកំណត់ហេតុស្តីពីការខ្វែងយោបល់គ្នា គឺមិនស្របគ្នាទៅនឹងកម្មវត្ថុ និងគោលបំណងនៃច្បាប់ជាធរមានទេ ។

ខ. ជាបញ្ហាទូទៅ មិនគិតថាតើវិធានតម្រូវឱ្យ (ដែលផ្ទុយទៅនឹង អនុញ្ញាតឱ្យ) មានការផ្ទេរអំណាច ឬ ធ្វើកំណត់ហេតុស្តីពីការខ្វែងយោបល់គ្នានៅមុនពេលដែលសហព្រះរាជអាជ្ញាម្នាក់បំពេញកិច្ចការដោយខ្លួនឯងនោះឡើយ សហព្រះរាជអាជ្ញាអន្តរជាតិសូមជូនសេចក្តីសន្និដ្ឋានថា វាមិនបានតម្រូវឱ្យធ្វើដូច្នោះទេនៅក្នុងករណីបច្ចុប្បន្ននេះ ។ ការខ្វែងយោបល់ដំបូងដែលបានធ្វើកំណត់ហេតុទាក់ទងទៅនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនៅក្នុងសំណុំរឿងលេខ ០០៣ បានគ្របដណ្តប់ទៅលើគ្រប់សកម្មភាពបន្តបន្ទាប់ទៀតទាំងអស់ ដែលធ្វើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិក្នុងសំណុំរឿងលេខ ០០៣ ។ ហេតុដូច្នោះហើយ ដើម្បីដាក់សំណើនានា មិនចាំបាច់មានការធ្វើកំណត់ហេតុថ្មី ស្តីពីការខ្វែងយោបល់គ្នាទៀតទេ ។ ការបកស្រាយច្បាប់ជាធរមានរបស់ សចស នឹងនាំឆ្ពោះទៅរកលទ្ធផលមួយដែលមិនសមហេតុសមផលទេ កាលណាការបំពេញកិច្ចជាបន្តបន្ទាប់នីមួយៗ ដោយមិនគិតថាវាជាកិច្ចតូចតាច ត្រូវបានធ្វើឡើងដោយព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងទៅនឹងសំណុំរឿងលេខ ០០៣ ដែលតម្រូវឱ្យមានការផ្ទេរអំណាច ឬ ការធ្វើកំណត់ហេតុតាមផ្លូវការនូវការខ្វែងយោបល់គ្នា នៅក្នុងកាលៈទេសៈដែលមូលហេតុនៃការខ្វែងយោបល់គ្នាមិនមានការប្រែប្រួល ឬ មិនមានវិវត្តឡើង ចាប់តាំងពីការខ្វែងយោបល់គ្នាដំបូងត្រូវបានធ្វើកំណត់ហេតុរួចមក ។

គ. ជាជម្រើសម៉្យាងទៀត នៅក្នុងករណីដែល អបជ យល់ឃើញថា ការផ្ទេរសិទ្ធិអំណាច ឬ កំណត់ហេតុស្តីពីការខ្វែងយោបល់គ្នា បានតម្រូវឱ្យធ្វើដើម្បីឱ្យសហព្រះរាជអាជ្ញាអន្តរជាតិអាចដាក់សំណើនានាបានតែម្នាក់ឯងនោះ សហព្រះរាជអាជ្ញាអន្តរជាតិសូមជូនសេចក្តី

00712884



សន្និដ្ឋានថា សចស បានខុសឆ្គងនៅក្នុងការបដិសេធសំណើទាំងនោះដោយមកពីគ្មានសុពលភាព ។ ដោយឡែក៖

(i) ដោយប្រកាសថាសំណើទាំងនេះគ្មានសុពលភាព គឺ ស.ច.ស បានខកខានមិនបានគិតគូរទៅលើគោលការណ៍ជាមូលដ្ឋានដែលមានចែងក្នុងវិធាន២១ ។ វិធាន ២១ ចែងថា នៅគ្រប់កាលៈទេសៈទាំងអស់ ភាពយុត្តិធម៌ តម្លាភាព និង ភាពច្បាស់លាស់តាមផ្លូវច្បាប់នៃដំណើរការនីតិវិធី ត្រូវតែយកមកពិចារណា ។ វិធាន ២១ ក៏បានផ្តល់អាណត្តិផងដែរថា តុល្យភាពនៃសិទ្ធិរបស់ភាគីទាំងអស់ ដោយរួមទាំងសិទ្ធិរបស់សហព្រះរាជអាជ្ញា និងជនរងគ្រោះផង ត្រូវតែបានថែរក្សា ។ ពាក់ព័ន្ធទៅនឹងសំណើសុំឱ្យបំពេញការស៊ើបសួរទាំងបី សិទ្ធិរបស់សហព្រះរាជអាជ្ញាក្នុងការតាមឃ្លាំមើល និងធានាលើការស៊ើបសួរដែលត្រូវតែអនុវត្តដោយទៀងត្រង់នោះ គឺបានទទួលរងនូវការខូចខាត ។ ពាក់ព័ន្ធទៅនឹងសំណើសុំពន្យារពេល ក្នុងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សិទ្ធិរបស់ជនរងគ្រោះត្រូវបានប៉ះពាល់ ។ ពាក់ព័ន្ធទៅនឹងគោលការណ៍នៃវិធាន ២១ សចស ត្រូវតែ ហើយអាចយ៉ាងងាយស្រួលបំផុត ផ្តល់នូវកាលានុវត្តភាពមួយដល់សហព្រះរាជអាជ្ញាអន្តរជាតិដើម្បីដោះស្រាយលើកង្វះខាតខាងនីតិវិធី ដែលត្រូវបានគេមើលឃើញនៅក្នុងសំណើទាំងនោះ ជាជាងបដិសេធសំណើចោលភ្លាមៗ។

(ii) ជម្រើសមួយបន្ថែមទៀត ការខកខានរបស់ សចស មិនបានពិចារណាលើខ្លឹមសារនៃសំណើទាំងនេះ គឺបានបំពារបំពានដល់កាតព្វកិច្ចតាមផ្លូវច្បាប់របស់ សចស ក្នុងការផ្តល់នូវការស៊ើបសួរមួយដែលមិនលំអៀង និងទាំងស្រុង ។

១០. ដោយគិតទៅដល់ខាងមុខ សហព្រះរាជអាជ្ញាអន្តរជាតិ សូមស្នើឱ្យ អង្គបុរេជំនុំជម្រះ បដិសេធដីកាសម្រេចរបស់ សចស ហើយ បង្គាប់ឱ្យ សចស ធ្វើការពិចារណាលើអង្គសេចក្តីនៃសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ។ បន្ថែមលើនេះ ពាក់ព័ន្ធទៅនឹងសារសំខាន់ជាស្នូលនៃបញ្ហានេះ ចំពោះសុចរិតភាព និងកិត្តិស័ព្ទជាសាធារណៈរបស់ អ.វ.ត.ក នីតិវិធីផ្ទៃក្នុង ក្នុងការបំពេញកិច្ចរបស់ កសព និងផលប៉ះពាល់ដែលអាចនឹងមាននៅគ្រប់ជំហាននីមួយៗទៅថ្ងៃខាងមុខ ដែលសហព្រះរាជអាជ្ញាអន្តរជាតិ ត្រូវបំពេញនៅក្នុងសំណុំរឿងលេខ ០០៣ និង ០០៤ នោះ សហព្រះរាជអាជ្ញាអន្តរជាតិ សូមស្នើដល់ អង្គបុរេជំនុំជម្រះ ចេញដីកាសម្រេចរបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍នេះ ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន ។

## ៤. អំពីច្បាប់ជាធរមាន

១១. មាត្រា ៦.៤ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ចែងថា៖ "ក្នុងករណីដែលព្រះរាជអាជ្ញា មិនអាចឯកភាពគ្នាថា ត្រូវបន្តការចោទប្រកាន់ណាមួយ *ការចោទ*

*ប្រកាន់នោះ ត្រូវដំណើរការទៅមុខទៀត* លើកលែងតែព្រះរាជអាជ្ញាទាំងពីរនេះ ឬ ព្រះរាជអាជ្ញាណាមួយក្នុងចំណោមព្រះរាជអាជ្ញាទាំងពីរ ធ្វើការស្នើសុំនៅក្នុងរយៈពេលសាមសិបថ្ងៃឱ្យដោះស្រាយការខ្វែងគំនិតគ្នានេះ តាមមាត្រា ៧" ។ [សង្កត់ន័យបន្ថែមដោយ *អក្សរទ្រេត*]

១២. មាត្រា២០ថ្មី នៃច្បាប់ អវតក ចែងថា៖ "[...] ក្នុងករណីដែលមានភាពខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា ត្រូវអនុវត្តគោលការណ៍ដូចខាងក្រោម៖ *ការចោទប្រកាន់ត្រូវបន្ត* ដរាបណាសហព្រះរាជអាជ្ញា ឬក៏ សហព្រះរាជអាជ្ញាម្នាក់ពុំបានស្នើក្នុងរយៈពេលសាមសិបថ្ងៃថា ភាពខ្វែងយោបល់គ្នា ត្រូវបានដោះស្រាយ ដោយអនុលោមតាមបទប្បញ្ញត្តិដូចខាងក្រោម" និង "សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ដែលពុំមានបើកផ្លូវឱ្យមានបណ្តឹងឧទ្ធរណ៍ តម្រូវឱ្យមានសម្លេងវិជ្ជមានពីចៅក្រមបួនរូបយ៉ាងតិច ។ [...] ប្រសិនបើពុំមានមតិភាគច្រើន ដូចតម្រូវឱ្យមានចំពោះការធ្វើសេចក្តីសម្រេចទេ *ការចោទប្រកាន់ត្រូវធ្វើបន្ត* ទៅទៀត" ។ [សង្កត់ន័យបន្ថែមដោយ *អក្សរទ្រេត*]

១៣. វិធាន ១.២ ចែងថា៖ "[...] ជាពិសេសលើកលែងតែមានចែងផ្សេងពីនេះ ការយោងនៅក្នុងវិធានផ្ទៃក្នុងនេះចំពោះពាក្យសហចៅក្រមស៊ើបអង្កេត សំដៅទៅដល់សហចៅក្រមស៊ើបអង្កេតទាំងពីរដែលធ្វើការសម្រេចចិត្តរួមគ្នា និងចៅក្រមស៊ើបអង្កេតណាម្នាក់ក្នុងចំណោមអ្នកទាំងពីរ ទោះបីដោយផ្ទាល់ ឬ តាមរយៈអ្នកតំណាង ។ *ករណីដូចគ្នានេះដែរត្រូវយកមកអនុវត្តចំពោះសហព្រះរាជអាជ្ញា*" ។ [សង្កត់ ន័យបន្ថែមដោយ *អក្សរទ្រេត*]

១៤. វិធាន ១៣.១ "ការិយាល័យសហព្រះរាជអាជ្ញា *ត្រូវធ្វើសកម្មភាពដោយឯករាជ្យ*នៅក្នុង អវតក" ។ វិធាន ១៣.៣ "វៀរលែងតែសកម្មភាពទាំងឡាយដែលត្រូវធ្វើរួមគ្នា ក្រោមច្បាប់ស្តីពីការបង្កើត អវតក និងវិធានផ្ទៃក្នុងនេះ សហព្រះរាជអាជ្ញា*អាច* ផ្ទេរអំណាចទៅឱ្យព្រះរាជអាជ្ញាណាមួយក្នុងចំណោមសហព្រះរាជអាជ្ញាទាំងពីររូប តាមរយៈសេចក្តីសម្រេចរួមគ្នាជាលាយលក្ខណ៍អក្សរដើម្បីឱ្យបំពេញកិច្ចការតែម្នាក់ឯងបាន" ។ [សង្កត់ន័យបន្ថែមដោយ *អក្សរទ្រេត*]

១៥. វិធាន ៧១.១ "ក្នុងករណីមានការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា សហព្រះរាជអាជ្ញាណាមួយ ឬទាំងពីរ*អាច*ធ្វើកំណត់ហេតុអំពីមូលហេតុពិតប្រាកដនៃការខ្វែងយោបល់គ្នានេះ[...]"។ វិធាន ៧១.២ "ក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ សហព្រះរាជអាជ្ញាណាម្នាក់*អាច*នាំយកករណីខ្វែងយោបល់គ្នានេះទៅចំពោះមុខអង្គបុរេជំនុំជម្រះ តាមរយៈការបញ្ជូនឯកសារអំណះអំណាងជាលាយលក្ខណ៍អក្សរអំពីហេតុការណ៍ និងមូលហេតុនៃការខ្វែងយោបល់គ្នានេះ[...]" ។ វិធាន ៧១.៣ "[...] *កិច្ច ឬ សេចក្តីសម្រេចដែលជាកម្មវត្ថុនៃការខ្វែងយោបល់គ្នានេះត្រូវតែយកទៅអនុវត្តលើកលែងតែ* បញ្ហានៃការខ្វែងយោបល់គ្នាពាក់ព័ន្ធទៅនឹងចំណុចដូចខាង ក្រោមនេះ៖ ក- ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, ខ- ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋថ្មី, គ- ដីកាសន្និដ្ឋានស្ថាពរ, ឬ ឃ- សេចក្តីសម្រេចពាក់ព័ន្ធទៅនឹងការប្តឹងឧទ្ធរណ៍[...]" ។ វិធាន ៧១.៤ "អង្គបុរេជំនុំជម្រះ ត្រូវដោះស្រាយបញ្ហាខ្វែងយោបល់គ្នានេះ ដូចខាងក្រោម៖ [...] គ- សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ តម្រូវឱ្យមានសម្លេងគាំទ្រពីចៅក្រម ៤(បួន)រូប

យ៉ាងតិច ។ [...] ប្រសិនបើអង្គបុរេជំនុំជម្រះ មិនអាចរកបានសម្លេងគាំទ្រភាគច្រើនតាមការតម្រូវទេ ដោយអនុលោមតាមមាត្រា ២០ថ្មី នៃច្បាប់ស្តីពីការបង្កើត អវតក *សេចក្តីសម្រេចដែលមិនមានសម្លេងគាំទ្រភាគច្រើនមានន័យថា កិច្ច ឬ សេចក្តីសម្រេចដែលបានធ្វើដោយសហព្រះរាជអាជ្ញាណាម្នាក់ត្រូវមានសុពលភាព ឬ មានន័យថា កិច្ច ឬ សេចក្តីសម្រេច ដែលបម្រុងនឹងធ្វើដោយសហព្រះរាជអាជ្ញាម្នាក់ត្រូវតែយកមកអនុវត្ត*" ។ [សង្កត់ន័យបន្ថែមដោយ *អក្សរទ្រេត*]

## ៥ អំណះអំណាង

### ៥(ក). ដីកាដែលកំពុងតវ៉ាមានមូលដ្ឋាននៅលើការបកស្រាយច្បាប់មិនត្រឹមត្រូវ

១៦. សចស មានការខុសឆ្គងនៅក្នុងការបកស្រាយច្បាប់ជាធរមាន ដោយបានសន្និដ្ឋានថាលើសំណើទាំងឡាយ គ្មានសុពលភាព ដោយមកពីអវត្តមាននៃការផ្ទេរអំណាច តាមមាត្រា ១៣.៣ ឬ មកពីអវត្តមាននៃកំណត់ហេតុតាមទម្រង់ការស្តីពីការខ្វែងយោបល់គ្នា ដោយសហព្រះរាជអាជ្ញាម្នាក់ ក្នុងចំណោមសហព្រះរាជអាជ្ញាទាំងពីរ តាមមាត្រា ៧១.១ ។

*(១) សេចក្តីសម្រេចដើម្បី ផ្ទេរអំណាច ឬ ធ្វើកំណត់ហេតុស្តីពីការខ្វែងយោបល់គ្នា គឺ តាមជម្រើស(optional) មិនមែន ដាច់ខាត(mandatory) ទេ*

១៧. វាជាការមួយច្បាស់លាស់ទៅតាមការអានតាមន័យត្រង់ៗនៃវិធាន ដែលថាសេចក្តីសម្រេចផ្ទេរអំណាច ឬ ធ្វើកំណត់ហេតុស្តីពីការខ្វែងយោបល់គ្នា គឺធ្វើ តាមជម្រើស មិនមែន ដាច់ខាត ទេ ។ ទាក់ទងទៅនឹងការផ្ទេរអំណាច វិធាន ១៣.៣ ចែងថា សហព្រះរាជអាជ្ញា "អាច"(may) ជ្រើសរើសក្នុងការផ្ទេរអំណាច ។ ស្រដៀងគ្នានេះដែរ ការធ្វើកំណត់ហេតុស្តីពីការខ្វែងយោបល់គ្នា វិធាន ៧១.១ បានប្រើពាក្យ "អាច"(may) ជាជំនួសពាក្យ "ត្រូវតែ"(shall) ។ ពាក្យថា "អាច" (may) នេះក៏ត្រូវបានប្រើផងដែរនៅក្នុងវិធាន ៧១.២ ដោយមានការបញ្ជាក់ថា សេចក្តីសម្រេចថាតើត្រូវនាំយកការខ្វែងយោបល់គ្នាទៅចំពោះមុខ អបជ គឺជាសេចក្តីសម្រេចដោយស្ម័គ្រចិត្តទាំងស្រុងរបស់សហព្រះរាជអាជ្ញាណាម្នាក់ក៏ដោយ ។ ជាមតិផ្ទុយពីនេះទៅវិញ សចស បានកត់សម្គាល់ថា កាលណាការខ្វែងយោបល់គ្នាត្រូវបានធ្វើកំណត់ហេតុ គឺគ្មានកាតព្វកិច្ចនាំយកការខ្វែងយោបល់គ្នានោះទៅចំពោះមុខអង្គបុរេជំនុំជម្រះទេ ដែលតាមន័យនេះ ហាក់ដូចជាបានទទួលស្គាល់អំពីលក្ខណៈ តាមជម្រើស នៃនីតិវិធីដោះស្រាយការខ្វែងយោបល់គ្នា[19] ។ សចស មិនមានការទៀងទាត់ទេ នៅពេលធ្វើការបកស្រាយខុសៗគ្នាលើពាក្យ "អាច"(may) តែមួយ៖ ខណៈដែលបកស្រាយនៅក្នុងវិធាន ៧១.១ គឺបានដាក់ឱ្យមានជា កាតព្វកិច្ចមួយ រីឯការបកស្រាយក្នុងវិធាន ៧១.២ ពាក្យថា "អាច"(may) មិនបង្កើតបានជាកាតព្វកិច្ចក្នុងការនាំយកការខ្វែងយោបល់គ្នា ទៅចំពោះមុខ អបជ ទេ[20] ។

---

[19] ដីកាដែលកំពុងតវ៉ា, កថាខណ្ឌទី ១១ ។

[20] ដីកាដែលកំពុងតវ៉ា, កថាខណ្ឌទី ១១ ។

១៨. អបជ ធ្លាប់បានឯកភាពជាមួយនឹងការបកស្រាយនេះ "មាត្រា ៦(១) និង(៤) នៃកិច្ចព្រមព្រៀង, មាត្រា ១៦ និង២០(ថ្មី) នៃច្បាប់ អ.វ.ត.ក និងវិធាន ៧១(៣) នៃវិធានផ្ទៃក្នុង បានបង្ហាញយ៉ាងច្បាស់លាស់ថា ព្រះរាជអាជ្ញាមួយអាចធ្វើសកម្មភាព ដោយគ្មានការព្រមព្រៀងពីព្រះរាជអាជ្ញាមួយទៀតបាន ប្រសិនបើពុំមានព្រះរាជអាជ្ញាណាមួយនាំយកនូវការខ្វែងយោបល់នេះមកដោះស្រាយនៅចំពោះមុខអង្គបុរេជំនុំជម្រះ នៅក្នុងពេលវេលាដែលបានកំណត់ជាក់លាក់ទេនោះ ។ អង្គបុរេជំនុំជម្រះក៏បានសង្កេតឃើញថែមទៀតថា មានតែពេលដែលបញ្ហាគួរឱ្យព្រួយបារម្ភដ៏សំខាន់ ដែលបានកំណត់បង្ហាញអត្តសញ្ញាណយ៉ាងជាក់លាក់នៅក្នុងវិធានផ្ទៃក្នុងមានការពាក់ព័ន្ធប៉ុណ្ណោះ ទើបការខ្វែងយោបល់គ្នានេះនឹងរារាំងព្រះរាជអាជ្ញាមួយ មិនឱ្យបន្តសកម្មភាពណាមួយ ដោយត្រូវផ្អាករង់ចាំរហូតមានសេចក្តីសម្រេចពីអង្គបុរេជំនុំជម្រះ ។ ក្នុងចំណោមចំណុចពិសេសទាំងនោះ គឺមានចំណុចនៃការខ្វែងយោបល់គ្នា ទាក់ទងទៅនឹងការចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យសើបសួរមួយ ដែលកំពុងតែជាបញ្ហា"[21] ។

១៩. ការយល់ឃើញរបស់ អបជ ទៅលើកិច្ចព្រមព្រៀង, ច្បាប់ អតក និង វិធានផ្ទៃក្នុង បានស្នើឡើងថា គោលការណ៍ជាមូលដ្ឋានទាក់ទងទៅនឹងការខ្វែងយោបល់គ្នា គឺថានីតិវិធី (ក្នុងការចោទប្រកាន់ ឬការស៊ើបសួរ) ត្រូវតែបន្តទៅមុខទៀត វៀរលែងតែវាត្រូវបានបញ្ជូនទៅអង្គបុរេជំនុំជម្រះ ហើយនិងក្តីបារម្ភចំពោះអំពើជាក់លាក់ដូចដែលបានចែងនៅក្នុងវិធាន ៧១.៣(ក)-(ឃ) នៃវិធានផ្ទៃក្នុង ។ ទោះជាយ៉ាងនេះក្តី សូម្បីតែនៅពេលនោះក៏ដោយ ក៏សកម្មភាព ឬសេចក្តីសម្រេចរបស់សហព្រះរាជអាជ្ញារូបនោះគឺគ្រាន់តែត្រូវបានព្យួរប៉ុណ្ណោះ បើចៅក្រម អបជ ត្រូវបានគេបញ្ជូនការខ្វែងយោបល់គ្នានោះឱ្យសម្រេចសេចក្តី ហើយភាគច្រើនលើសលុបបានសម្រេចបញ្ឈប់សកម្មភាព ឬសេចក្តីសម្រេចរបស់សហព្រះរាជអាជ្ញារូបនោះ ។

### *(២) ការអនុវត្តន៍ក្នុងការដាក់ឯកសារតែម្នាក់ឯង កាលពីមុនមក ធ្លាប់ត្រូវបានយល់ព្រមដោយ សចស*

២០. ផ្ទុយពីការពោលអះអាងរបស់ សចស ដូចមាននៅក្នុងដីកាដែលកំពុងមានការតវ៉ា ការអនុវត្តន៍ក្នុងការដាក់ឯកសារតែម្នាក់ឯងធ្លាប់ត្រូវបានទទួលការយល់ព្រមដោយសហចៅក្រមស៊ើបអង្កេតទាំងពីររូប ឬដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិតែម្នាក់ឯង នៅក្នុងពេលកន្លងមក។ ឧទាហរណ៍មួយចំនួនអំពីថាការអនុវត្តន៍បែបនេះត្រូវបានគេអនុម័តយក គឺមានដូចខាងក្រោមនេះ៖

---

[21] អបជ, ឧបសម្ព័ន្ធ ១៖ សំណៅសាធារណៈមានកោសលុប, សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង, ថ្ងៃទី១៨ សីហា ២០០៧, D1/1.3, កថាខណ្ឌទី ១៦ ។

២១. កាលពីថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលបំពេញកិច្ចតែម្នាក់ឯង បានស្វែងរកសុំការបំភ្លឺ[22]ពីសហព្រះរាជអាជ្ញាអន្តរជាតិតែម្នាក់ប៉ុណ្ណោះ ទាក់ទងអំពីវិសាលភាពនៃកិច្ចស៊ើបសួរ។ សហចៅក្រមស៊ើបអង្កេតមិនបានផ្ញើទៅឱ្យសហព្រះរាជអាជ្ញាជាតិទេ[23]។ សហចៅក្រមស៊ើបអង្កេតបានលើកទឡ្ហីករណ៍នៅក្នុងដីកាដែលកំពុងមានការតវ៉ាថា ប្រការដែលសំណើសុំការបំភ្លឺត្រូវបានផ្ញើទៅឱ្យតែសហព្រះរាជអាជ្ញាអន្តរជាតិ(ICP)តែម្នាក់គត់ ហើយមិនផ្ញើទៅឱ្យសហព្រះរាជអាជ្ញាទាំងពីរនោះគឺគ្មានន័យអ្វីនោះទេ ដោយ"គ្រាន់តែមានន័យថា គោលបំណងគឺចង់ឱ្យ (សហព្រះរាជអាជ្ញាអន្តរជាតិ) ជាអ្នកទទួលឯកសារតែប៉ុណ្ណោះ"។ ទឡ្ហីករណ៍នេះគឺមិនអាចទទួលយល់ព្រមបានឡើយ។ ផ្ទុយទៅវិញ ការផ្ញើសំណើនេះទៅឱ្យតែសហព្រះរាជអាជ្ញាអន្តរជាតិម្នាក់គត់ប៉ុណ្ណោះនោះ គឺជាការបង្ហាញឱ្យឃើញច្បាស់នៅក្នុងពេលនោះ អំពីការទទួលស្គាល់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ(សចស)ថា លោកអាចស្នើសុំការបំភ្លឺបានតែពីសហព្រះរាជអាជ្ញាអន្តរជាតិប៉ុណ្ណោះ ព្រោះអនុលោមតាមការពិចារណារបស់ អបជ ថា សហព្រះរាជអាជ្ញាអន្តរជាតិគឺជាបុគ្គលតែម្នាក់ប៉ុណ្ណោះដែលមានសិទ្ធិអំណាចតាមច្បាប់ដើម្បីបកស្រាយខ្លឹមសារនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដែលបានដាក់មកដោយសហព្រះរាជអាជ្ញាអន្តរជាតិតែម្នាក់ឯង។ សហចៅក្រមស៊ើបអង្កេត(ទាំងពីរ) បានទទួលស្គាល់អំពីតក្កភាពនៃការបកស្រាយអំពីវិធានផ្ទៃក្នុងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ។

២២. រឿងនេះត្រូវបានបង្ហាញឱ្យឃើញបន្ថែមទៀតដោយអង្គហេតុជាក់ស្តែងថា សហចៅក្រមស៊ើបអង្កេតទាំងពីរបានយល់ព្រមចំពោះការដាក់ឯកសារពីសហព្រះរាជអាជ្ញាអន្តរជាតិតែម្នាក់ឯងថាមានសុពលភាពនោះ ដែលឯកសារនោះបានផ្ញើទៅជូន សចស ទាំងពីរនាក់ និងដែលបានឆ្លើយតបទៅនឹងសំណើសុំការបំភ្លឺរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិតែម្នាក់ប៉ុណ្ណោះ[24]។ ជាថ្មីម្តងទៀតនៅទីនេះ ការផ្តល់ហេតុផលដោយ សចស (ទាំងពីរ)ដើម្បីបញ្ជាក់ថាជាការត្រឹមត្រូវដូចដែលមាននៅក្នុងដីកាដែលកំពុងមានការតវ៉ានេះ គឺមិនអាចជួយការពារបានឡើយ។ ពួកគេបានលើក

---

[22] ដីកាដែលកំពុងមានបញ្ហា មានបញ្ជាក់នៅក្នុងកថាខណ្ឌទី៦ (៣)ថា ការខ្វែងយោបល់គ្នាមួយអនុលោមតាមវិធាន១៤.៧ នៃវិធានក្នុងបច្ចុប្បន្ននេះត្រូវបានសហចៅក្រមស៊ើបអង្កេតចុះនៅក្នុងកំណត់ហេតុ និងដាក់ចូលនៅក្នុងបញ្ជីសំរាប់ការខ្វែងយោបល់គ្នាស្របតាមវិធាន៧២.១ ដែលពន្យល់ថា តើហេតុអ្វីបានជាត្រូវបានដាក់មកដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ឯង ។

[23] សហចៅក្រមស៊ើបអង្កេតអន្តរជាតិ, សំណើសុំការបំភ្លឺនៅក្នុងសំណុំរឿងលេខ០០៣, ចុះថ្ងៃទី៨ កុម្ភៈ ២០១១, ឯកសារលេខ D1/2, (ដែលផ្ញើជូនលោក Andrew Cayley(sic) សហព្រះរាជអជ្ញាអន្តរជាតិតែម្នាក់គត់ប៉ុណ្ណោះ) ។

[24] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើសុំការបំភ្លឺ, ចុះថ្ងៃទី១៦ កុម្ភៈ ២០១១, ឯកសារលេខ D1/2/1, (ដែលផ្ញើដោយសហព្រះរាជអាជ្ញារងអន្តរជាតិទៅជូនសហចៅក្រមស៊ើអង្កេតទាំងពីរ) ។

ឡើងតវ៉ាថា“[...]សហចៅក្រមស៊ើបអង្កេតបានឈប់លែងបង្គាប់ឲ្យសហព្រះរាជអាជ្ញាបង្ហាញអំពីថាតើការផ្ទេរប្រគល់អំណាច ឬការចុះនៅក្នុងកំណត់ហេតុអំពីការខ្វែងយោបល់គ្នាមានបានធ្វើឡើងដែរឬទេ?ទៀតហើយ...[ពីព្រោះ] ខ្លឹមសារនៃចម្លើយតបបានទុកឲ្យវិសាលភាពនៃកិច្ចស៊ើបសួរឲ្យនៅដដែលគ្មានការកែប្រែអ្វីឡើយ”[25]។ គួរបានកត់សំគាល់ថា សចស (ទាំងពីរ) មិនដែលបានជូនដំណឹងទៅសហព្រះរាជអាជ្ញាទាល់តែសោះថា ពួកខ្លួនបាន[ឈប់លែង]បង្គាប់ឲ្យបង្ហាញឲ្យឃើញអំពីផ្ទេរប្រគល់អំណាច ឬការចុះនៅក្នុងកំណត់ហេតុអំពីការខ្វែងយោបល់គ្នាឡើយ ។ ជាងនេះទៅទៀត នៅមុនពេលចេញដីកាដែលកំពុងមានការតវ៉ា សចស (ទាំងពីរ) ក៏មិនដែលបានជូនដំណឹងដល់សហព្រះរាជអាជ្ញាទាល់តែសោះអំពីការបង្គាប់ឲ្យសហព្រះរាជអាជ្ញាបង្ហាញថាការផ្ទេរប្រគល់អំណាច ឬការចុះនៅក្នុងកំណត់ហេតុអំពីការខ្វែងយោបល់គ្នាដែលបានធ្វើឡើងនោះអាចជាលក្ខខណ្ឌតម្រូវជាមុនដែលចាំបាច់មួយសម្រាប់ឲ្យ សចស ផ្តល់ការយល់ព្រមលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិនោះដែរ។ បើសិនជា សចស ពិតជាមានបំណងចង់ទទួលបាននូវការឆ្លើយតបពីសហព្រះរាជអាជ្ញាទាំងពីរ (ឬមួយក៏ពីសហព្រះរាជអាជ្ញាតែម្នាក់ដោយការផ្ទេរប្រគល់អំណាចឬបន្ទាប់ពីបានចុះនៅក្នុងកំណត់ហេតុអំពីការខ្វែងយោបល់គ្នា)ពិតប្រាកដមែននោះ សំណើ ដែលស្វែងរកសុំការបំភ្លឺ មិនគួរបានផ្ញើទៅឲ្យសហព្រះរាជអាជ្ញាតែម្នាក់ក្នុងចំណោមទាំងពីរនាក់នោះឡើយ ។

២៣. កាលពីថ្ងៃទី៧ ខែមីនា ឆ្នាំ២០១១ យូរបន្តិចមុនបញ្ហាស្តីពីសុពលភាពនៃសំណើដែលដាក់តែម្នាក់ឯងនៅក្នុងសំណុំរឿងលេខ០០៣របស់សហព្រះរាជអាជ្ញាអន្តរជាតិនេះ សហព្រះរាជអាជ្ញាជាតិបានដាក់ដាច់ដោយឡែកតែម្នាក់ឯងជូនអង្គជំនុំជម្រះសាលាដំបូងនូវសំណើមួយនៅក្នុងសំណុំរឿងលេខ០០២។ លោកស្រីបានបែបនេះដោយមិនមានការផ្ទេរប្រគល់សិទ្ធិ ឬការចុះនៅក្នុងកំណត់ហេតុអំពីការខ្វែងយោបល់គ្នាណាមួយនោះឡើយ។ រហូតទល់បច្ចុប្បន្ននេះ ការដាក់ឯកសារនេះមិនបានធ្វើឲ្យមានការជំទាស់ណាមួយដោយអង្គជំនុំជម្រះសាលាដំបូងអំពីភាពអាចទទួលយកបាននោះឡើយ[26]។ នេះសរឲ្យឃើញថា តាមការយល់ឃើញរបស់សហព្រះរាជអាជ្ញាទាំងពីរ ការដាក់ឯកសារដែលធ្វើឡើងតែម្នាក់ឯងគឺអាចឲ្យទទួលយល់ព្រមបាន ។

២៤. ជាចុងក្រោយ ដូចបានគូសបញ្ជាក់រួចហើយនៅក្នុងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិថា សហព្រះរាជអាជ្ញាជាតិបានសំរេចកាលពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១១ថា ត្រូវដាក់ចម្លើយតប

[25] ដីកាដែលកំពុងមានបញ្ហា, កថាខណ្ឌទី៦ (៣)។

[26] សំណុំរឿងលេខ០០២, សំណើរបស់សហព្រះរាជអាជ្ញា(ជាតិ) សុំពន្យារពេលកំណត់ដើម្បីឆ្លើយតបទៅនឹងអញ្ញត្រកម្មចំពោះសាក្សី និងអ្នកជំនាញនានាដែលបានស្នើសុំដោយភាគីផ្សេងៗទៀត, ចុះថ្ងៃទី៧ មីនា ២០១១, ឯកសារលេខ E9/14/1/2 ។

ដាច់ដោយឡែកតែឯងមួយរបស់ខ្លួនផ្ទាល់ ទៅនឹងដីកាលើកទីមួយរបស់ សចស ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១១ ដោយមិនចាំបាច់មានការផ្ទេរប្រគល់អំណាច ឬការចុះនៅក្នុងកំណត់ហេតុអំពីការខ្វែងយោបល់គ្នាជាមុនឡើយ។ នេះជាការសរបញ្ជាក់ឱ្យឃើញថា តាមការយល់ឃើញរបស់លោកស្រី សំណុំបែបបទដូចនេះមិនមានការចាំបាច់ដើម្បីធ្វើឱ្យចម្លើយតបរបស់លោកស្រីអាចទទួលយកបាននោះឡើយ។ តាមមិតិដែលយល់ឃើញខុសពីគេ សចស(ទាំងពីរ)បានយល់ព្រមក្នុងពេលនេះថា ចម្លើយតបដែលធ្វើឡើងដោយសហព្រះរាជអាជ្ញាជាតិតែឯង គឺមានសុពលភាព[27]។ សហចៅសចស (ទាំងពីរ) ក៏បានយល់ព្រមផងដែរលើចម្លើយតបដែលដាក់សហព្រះរាជអាជ្ញាអន្តរជាតិតែម្នាក់ឯង កាលពីថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១១ និងបានសំរេចចិត្ត ធ្វើការសំរេចទៅលើអង្គសេចក្តីនៃចម្លើយតបនេះ[28] ។

២៥. ឧទាហរណ៍ផ្សេងៗ ដែលបានលើកយកជូនដូចខាងលើនេះសរឱ្យឃើញថា ការអនុវត្តក្នុងការដាក់ឯកសារតែម្នាក់ឯងគឺត្រូវបានទទួលយល់ព្រមដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិតែម្នាក់ឯងផង និងដោយសហចៅក្រមស៊ើបអង្កេតទាំងពីរនាក់ផង ។ នេះគឺជាការគាំទ្រដល់ការបកស្រាយអំពីវិធានផ្ទៃក្នុងរបស់សហព្រះរាជអាជ្ញាអន្តរជាតិថា ជាការប្រគល់អំណាចទៅឱ្យសហព្រះរាជអាជ្ញានូវសិទ្ធិក្នុងការផ្ទេរអំណាច ឬការចុះនៅក្នុងកំណត់ហេតុអំពីការខ្វែងយោបល់គ្នា តែមិនមែនជាការតម្រូវឱ្យធ្វើយ៉ាងនេះនោះទេ ។

២៦. ដោយសារតែការអនុវត្តន៍ដែលត្រូវបានទទួលយល់ព្រមនេះ សហព្រះរាជអាជ្ញាអន្តរជាតិមិនមានសញ្ញាបង្ហាញណាមួយដែលថា សចស នឹងផ្លាស់ប្តូរនូវការបកស្រាយច្បាប់ជាធរមានរបស់ខ្លួនភ្លាមៗហើយបដិសេធសំណើទាំងបួនស្តីពីបច្ចេកទេសដែលទាក់ទងនឹងនីតិវិធីនោះឡើយ ។ ផ្ទុយពីការដែលខ្លួនត្រូវថែរក្សាការពារភាពប្រាកដប្រជានៃច្បាប់ និងតម្លាភាពនៃដំណើរការនីតិវិធី សហចៅក្រមស៊ើបអង្កេតបែរជាកំពុងចូលរួមចំណែក នៅក្នុងការធ្វើមិនឱ្យច្បាប់មានភាពប្រាកដប្រជាទៅវិញ ដោយបានផ្លាស់ប្តូរការអនុវត្តន៍និងការបកស្រាយច្បាប់ជាធរមានរបស់ខ្លួនអាស្រ័យទៅតាមកាលៈទេសៈទៅវិញ ។ ដូចដែលបានលើកជាទឡ្ហីករណ៍ជជែកតវ៉ាបន្ថែមទៀតនៅក្នុងផ្នែក គ(២)និង(៣)ខាងក្រោមនេះ ប្រភេទនៃការប្រព្រឹត្តបែបនេះបង្ហាញអំពីការខ្វះសេចក្តីគោរពចំពោះភាពត្រឹមត្រូវយុត្តិធម៌ និងតម្លាភាពនៃដំណើរការនីតិវិធីទាំងនេះ និងចំពោះឯករាជ្យ និងការទទួលខុសត្រូវរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន២១ នៃវិធានផ្ទៃក្នុង ។

### *(៣) ការបកស្រាយរបស់សហចៅក្រមស៊ើបអង្កេត គឺមិនស្របគ្នាទៅនឹងកម្មវត្ថុនិងគោលបំណងនៃច្បាប់ជាធរមានឡើយ*

[27] ដីកាដែលកំពុងតវ៉ា, កថាខណ្ឌទី៣ ។

[28] ដីកាដែលកំពុងតវ៉ា, កថាខណ្ឌទី៣ ។

២៧. ការបកស្រាយរបស់ សចស អំពីវិធានថាបានតម្រូវឱ្យមានការផ្ទេរអំណាច ឬចុះការខ្វែងយោបល់គ្នានៅក្នុងកំណត់ហេតុ គឺមិនស្របទៅនឹងកម្មវត្ថុនិងគោលបំណងនៃច្បាប់ជាធរមានដែលត្រូវផ្តល់យន្តការមួយសំរាប់សហព្រះរាជអាជ្ញាតែមួយរូបដើម្បីជំរុញឱ្យការចោទប្រកាន់បានដំណើរការទៅមុខនៅក្នុងកាលៈទេសដ៏សមស្រប ហើយលុះត្រាតែសហព្រះរាជអាជ្ញាត្រូវបានផ្តល់នូវឱកាសដើម្បីលើកឡើងនូវអញ្ញត្រកម្មណាមួយចំពោះបណ្តឹងចោទប្រកាន់ដែលបានស្នើឡើង។ នេះគឺជាការធានាឱ្យដំណើរការនីតិវិធីអាចជឿនលឿនទៅមុខក្នុងលក្ខណៈដ៏ឆាប់រហ័សមួយដើម្បីជាផលប្រយោជន៍របស់គ្រប់ភាគីទាំងអស់ និងរបស់ជនរងគ្រោះផង។

២៨. នៅក្នុងសំណុំរឿងបច្ចុប្បន្ននេះ កម្មវត្ថុនិងគោលបំណងនៃច្បាប់ជាធរមានត្រូវបានបំពេញយ៉ាងច្បាស់ ដោយការផ្តល់នូវឱកាសគ្រប់គ្រាន់ឱ្យសហព្រះរាជអាជ្ញាជាតិដើម្បីអនុវត្តសិទ្ធរបស់លោកស្រីតាមវិធាន១៣.៣ឬវិធាន៧១.១នៃវិធានផ្ទៃក្នុង និងមានសេរីភាពក្នុងការសំរេចថាមិនធ្វើដូច្នេះ។

២៩. នៅក្នុងដីកាទីមួយរបស់ខ្លួនចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១១ សចស បានសំរេចថា នៅពេលប្រឈមមុខនឹងបណ្តឹងដែលធ្វើមកដោយសហព្រះរាជអាជ្ញាណាម្នាក់ឯងនោះ សចស ត្រូវមានកាតព្វកិច្ច "ដើម្បីបញ្ជាក់ឱ្យច្បាស់លាស់ថាតើសហព្រះរាជអាជ្ញាជាតិមានត្រូវបានគេផ្តល់ឱកាសឱ្យដើម្បីឱ្យអនុវត្តនូវសិទ្ធិរបស់ខ្លួនស្របតាមវិធាន១៣.៣ និងវិធាន៧១.១នៃវិធានផ្ទៃក្នុង ដែរឬទេ?"[29]។ ប៉ុន្តែ នៅក្នុងដីកាដែលកំពុងតែមានការតវ៉ារបស់ខ្លួន សហចៅក្រមស៊ើបអង្កេត(ទាំងពីរ)មិនមាននិយាយអ្វីទាល់តែសោះទាក់ទងនឹងថា តើសហព្រះរាជអាជ្ញាជាតិមានត្រូវបានគេផ្តល់ឱកាសណាមួយដើម្បីឱ្យអនុវត្តនូវសិទ្ធិរបស់ខ្លួនដែរឬទេ? [30]។ ផ្ទុយទៅវិញ សហចៅក្រមស៊ើបអង្កេតបានផ្តោតតែទៅលើថា តើមានការផ្ទេរប្រគល់សិទ្ធអំណាចតាមវិធាន១៣.៣ ដែរឬទេ? ឬតើការខ្វែងយោបល់គ្នាមានត្រូវបានចុះនៅក្នុងកំណត់ហេតុអនុលោមតាមវិធាន៧១.១ នៃវិធានផ្ទៃក្នុង ហើយឬនៅ ? តែប៉ុណ្ណោះគត់[31] ។

៣០. តាមពិត សហព្រះរាជអាជ្ញាជាតិត្រូវបានជូនដំណឹងឱ្យដឹងរួចហើយអំពីខ្លឹមសារនៃសំណើទាំងនេះនៅមុនពេលដាក់ឯកសារទាំងនេះ ។ នៅក្នុងកិច្ចប្រជុំនានាដែលពិភាក្សាអំពីខ្លឹមសារនៃសំណើនេះ សហព្រះរាជអាជ្ញាជាតិបានថ្លែងថា មិនចុះនៅក្នុងកំណត់ហេតុនូវការខ្វែងយោបលើគ្នាណាមួយលើសំណើទាំងនេះដូចដែលបានរៀបរាប់នៅក្នុងវិធាន៧១.១ នៃវិធានផ្ទៃក្នុងទេ ហើយលោកស្រីក៏មិនមានបំណងចង់ឱ្យផ្ទេរអំណាចណាមួយរបស់ខ្លួនទៅឱ្យសហព្រះរាជអាជ្ញាអន្តរជាតិ អនុលោមតាមវិធាន១៣.៣នៃវិធានផ្ទៃក្នុងនោះដែរ ។ អាចឱ្យទាញជាសេចក្តីសន្និដ្ឋានពីក្នុងនេះបានថា តាមយោបល់របស់ សហព្រះរាជអាជ្ញាអន្តរជាតិទម្រង់បែបបទនេះ មិនមានការចាំបាច់នោះទេហើយក៏មិនចង់ឱ្យមានដែរនៅក្នុងករណីរឿងបច្ចុប្បន្ននេះ ។អនុលោមតាមដីកាដែលកំពុងមានការតវ៉ារបស់

[29] ដីកាលើកទីមួយ, ទំព័រ២ ។

[30] ដីកាដែលកំពុងតវ៉ា, កថាខណ្ឌទី៨ ។

[31] ដីកាដែលកំពុងតវ៉ា, កថាខណ្ឌទី៥-១១ ។

00712892



សហចៅក្រមស៊ើបអង្កេត គោលបំណងដែលស្ថិតនៅពីក្រោយការចុះការខ្វែងយោបល់គ្នាក្នុងកំណត់ហេតុអនុលោមតាមវិធាន៧១.១ នៃវិធានផ្ទៃក្នុងនោះ គឺដើម្បីផ្តល់នូវ "ភាពប្រាកដប្រជានៃច្បាប់និងតម្លាភាពនៃដំណើរការនីតិវិធីអនុលោមតាមវិធាន២១.១នៃវិធានផ្ទៃក្នុង"[32] ។ ដោយជូនដំណឹងគ្នាទៅវិញទៅមកជាប់ជាបន្តអំពីសេចក្តីសំរេច និងការដាក់ឯកសារដែលពួកខ្លួនមានបំណងចង់ធ្វើ និងដោយរក្សាជាងដែលនូវការខ្វែងយោបល់គ្នាពីដំបូងរបស់ពួកគេលើសំណុំរឿងលេខ០០៣ សហព្រះរាជអាជ្ញាបានផ្តល់ជូនទាំងពីរទាំងភាពប្រាកដប្រជានៃច្បាប់ផង និងទាំងតម្លាភាពដូចដែលសហចៅក្រមស៊ើបអង្កេតបានតម្រូវ និងវិធាន ២១.១នៃវិធានផ្ទៃក្នុងផង ។ សហចៅក្រមស៊ើបអង្កេតបានខកខានមិនបានយកចិត្តទុកដាក់លើបញ្ហាទាំងនេះនៅក្នុងពេលពិនិត្យពិចារណាអំពីសុពលភាពនៃសុំណើនានា ។

៣១. ដោយមិនបានការបំពេញសព្វគ្រប់តាមកម្មវត្ថុ និងគោលបំណងនៃច្បាប់ជាធរមាន ការបកស្រាយរបស់ សចស អំពីវិធាននឹងធ្វើឱ្យខូចដល់ច្បាប់ទាំងនេះដោយនាំទៅរកការអូសបន្លាយពេលវេលាដល់ដំណើរការនីតិវិធីដោយគ្មានការចាំបាច់ ។ ទោះបីជា ដូចការលើកឡើងរបស់ សចស នៅក្នុងដីកាដែលកំពុងតវ៉ានោះក៏ដោយ ក៏ការចុះការខ្វែងយោបល់គ្នានៅក្នុងកំណត់ហេតុអាចគ្រាន់តែជា "បញ្ហាទាក់ទងនឹងកំណត់ហេតុ"តែប៉ុណ្ណោះ ផលវិបាកនៃការធ្វើដូច្នេះអាចនឹងនាំឱ្យមានការអូសបន្លាយពេវេលាកាន់តែយូរជាងនេះនៅក្នុងការណីការដាក់ឯកសារខ្លះ ។ ដោយវិធីបង្ហាញឱ្យឃើញជាក់ស្តែង ការចុះក្នុងកំណត់ហេតុអំពីការខ្វែងយោបល់គ្នានៅមុនការដាក់ដីកាសន្និដ្ឋានបញ្ជូឱ្យស៊ើបសួរបន្ថែមនៅក្នុងសំណុំរឿងលេខ០០៤(បណ្តឹងដែលទាំងសហព្រះរាជអាជ្ញាអន្តរជាតិក្តី ទាំងសហព្រះរាអាជ្ញាអន្តរជាតិក្តីយល់ឃើញថាតាមវិធានគឺមិនមានការចាំបាច់ទេ) ជាលទ្ធផលគឺបណ្តាលឱ្យ សចស បដិសេធនូវដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដោយសារហេតុផលថា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមត្រូវបានដាក់មកនៅមុនកាលបរិច្ឆេទកំណត់ដែលមានចំនួន៣០ថ្ងៃត្រូវផុត ដូចដែលបានចែងកំណត់នៅក្នុងវិធាន៧១.៣ នៃវិធានផ្ទៃក្នុង[33]។

### ៥(ខ) សំណើទាំងបួន មានការទាក់ទងដោយផ្ទាល់ទៅនឹងការខ្វែងយោបល់គ្នាដែលធំជាងនេះ នៅក្នុងសំណុំរឿងលេខ០០៣

៣២. ដោយមិនគិតពីថាតើ ក្នុងនាមជាបញ្ហាទូទៅ វិធានបានតម្រូវ (ដែលផ្ទុយពីអនុញ្ញាត)ឱ្យមានការផ្ទេរអំណាច ឬការចុះការខ្វែងយោបល់គ្នានៅក្នុងកំណត់ហេតុមុនពេលសហព្រះរាជអាជ្ញាណាម្នាក់ចាត់វិធានការណ៍ណាមួយជាបុគ្គល សហព្រះរាជអាជ្ញាអន្តរជាតិសូមលើកឡើងថា ក្នុងករណីបច្ចុប្បន្ននេះ គឺមិនមានការតម្រូវនោះទេ ។

---

[32] ដីកាដែលកំពុងតវ៉ា, កថាខណ្ឌទី១១ ។

[33] ដីកាសម្រេចលើដីកាសម្រេចលើសេចក្តីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹង ទីតាំង ឧក្រិដ្ឋកម្មនៅតំបន់១និងការធ្វេទុក្ខបុកម្នេញខ្មែរក្រោម, ចុះថ្ងៃទី២៨ មិថុនា២០១១, ឯកសារលេខ D27/3 ។

៣៣. សំណើសុំទាំងនេះ មានការទាក់ទងដោយផ្ទាល់ទៅនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងនៅតែចាត់ចូលនៅក្នុងការខ្វែងយោបល់គ្នាកាលពីដំបូងជាងដែល ។ ការខ្វែងយោបល់គ្នាកាលពីដំបូងនៅក្នុងសំណុំរឿងលេខ០០៣ ត្រូវបានធ្វើសេចក្តីសន្និដ្ឋានដោយចៅក្រមនៃ អបជ កាលពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ នៅពេលដែលពួកគេខកខានមិនបានឈានទៅដល់ការធ្វើសេចក្តីសម្រេចលើបញ្ហានេះ ហើយបានកំណត់ថា អនុលោមតាមវិធាន៥៣១នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាអន្តរជាតិត្រូវបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដោយខ្លួនឯងផ្ទាល់ទៅឱ្យ សចស ដើម្បីបើកកិច្ចស៊ើបសួរ[34]។

៣៤. ហេតុដូចនេះ ផលវិបាកដែលមានតក្កភាពតែមួយគត់នៃនីតិវិធីអំពីការខ្វែងយោបល់គ្នាកាលពីដំបូងដូចដែលបានដោះស្រាយតាមរយៈការពិចារណារបស់អង្គបុរេជំនុំជម្រះនោះគឺថា សហព្រះរាជអាជ្ញាអន្តរជាតិគួរតែបន្តបំពេញកិច្ច (act)តែម្នាក់ឯងតទៅទៀត នៅពេលមានបណ្តឹងអាជ្ញាមួយ(a prosecutorial act) ទាក់ទងទៅនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ សំណើទាំងបួនដែលបានដាក់ក្នុងពេលថ្មីៗនេះ គឺទាំងអស់សុទ្ធតែមានប្រភពចេញមកពីបណ្តឹងដែលប្តឹងមកសហចៅក្រមស៊ើបអង្កេតពីដំបូង អំពីអង្គហេតុនៃបទល្មើសព្រហ្មទណ្ឌនានាដែលបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនោះ ។

៣៥. ប្រការដែលសហព្រះរាជអាជ្ញាជាតិបានសម្រេចមិនចុះហត្ថលេខាលើសំណើទាំងបួននេះ (នឹងលើការបំពេញកិច្ចជាបន្តបន្ទាប់មកទៀតដែលទាក់ទងនឹងសំណើទាំងនេះ) គឺជាការបង្ហាញឱ្យឃើញយ៉ាងច្បាស់អំពីការមិនយល់ព្រមរបស់លោកស្រីសហព្រះរាជអាជ្ញាជាតិជាបន្តបន្ទាប់ជាមួយសហព្រះរាជអាជ្ញាអន្តរជាតិចំពោះការចោទប្រកាន់ណាមួយបន្ថែមទៀតពីលើសំណុំរឿងលេខ០០១ និងលេខ០០២។ ជំហររបស់សហព្រះរាជអាជ្ញាជាតិលើបញ្ហានេះគឺគ្មានការប្រែប្រួលទាល់តែសោះ ចាប់តាំងពីមានការខ្វែងយោបល់លើកដំបូងនៅក្នុងសំណុំរឿងលេខ០០៣មក។ តាមពិត កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាជាតិបានចេញសេចក្តីថ្លែងការណ៍ជាសាធារណៈមួយបញ្ជាក់ពីការបន្តជំទាស់ជាប់រហូតមកចំពោះដំណើរការរឿងក្តីលើសំណុំរឿងលេខ០០៣[35]។

៣៦. ទោះបីជា សហព្រះរាជអាជ្ញាអន្តរជាតិដឹងអំពីការបន្តជំទាស់របស់សហព្រះរាជអាជ្ញាជាតិលើសំណុំរឿង០០៣នោះក៏ដោយក៏ ដើម្បីបញ្ជាក់តម្លាភាព បោរីភាព និងការរក្សានូវទំនាក់ទំនងផ្នែកវិជ្ជាជីវៈរវាងគ្នានឹងគ្នាឱ្យបានល្អប្រសើរបំផុត ជានិច្ចកាលគឺសហព្រះរាជអាជ្ញាអន្តរជាតិតែងតែបានធ្វើការជូនដំណឹងជាមុនដល់សហព្រះរាជអាជ្ញាជាតិអំពីបណ្តឹងទាក់ទងនឹងនីតិវិធីផ្សេងៗដែលខ្លួនមានបំណងចង់ដាក់នៅក្នុងសំណុំរឿងលេខ០០៣។ សហព្រះរាជអាជ្ញាអន្តរជាតិបានផ្តល់ជូននូវ

[34] អបជ ឧបសម្ពន្ធ១៖ អត្ថបទសំរាប់ជាសាធារណៈដែលមានការលុបចេញខ្លះ, ការពិចារណារបស់អង្គបុរេជំនុំជម្រះស្តីពីការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន៧១នៃវិធានផ្ទៃក្នុង, ចុះថ្ងៃទី១៨ សីហា ២០០៩, ឯកសារលេខ D1/1.3, កថាខណ្ឌទី៤៥ ។

[35] សេចក្តីថ្លែងរបស់សហព្រះរាជអាជ្ញាជាតិទាក់ទងនឹងសំណុំរឿងលេខ០០៣, ចុះថ្ងៃទី១០ ឧសភា ២០១១, ដែលអាចរកមើលបាននៅក្នុងគេហទំព័ររបស់ អវតក ។

ឯកសារជាលាយលក្ខណ៍អក្សរនៅមុននៅការដាក់ឯកសាររបស់ខ្លួន និងបានពិគ្រោះយោបល់ជាមួយលោកស្រីសហព្រះរាជអាជ្ញាជាតិដើម្បីធានាឱ្យប្រាកដថា ជំហររបស់លោកស្រីមិនមានការវិវត្តន៍ផ្លាស់ប្តូរនោះទេ ។

៣៧. ការបកស្រាយណាមួយអំពីកិច្ចព្រមព្រៀង ច្បាប់ អវតក ឬអំពីវិធានផ្ទៃក្នុងដែលតម្រូវឱ្យបណ្តឹងអាជ្ញាតូចតាចនីមួយៗនិង គ្រប់រាល់បណ្តឹងទាំងអស់ដែលមានការខ្វែងយោបល់គ្នាថ្មីត្រូវចុះនៅក្នុងកំណត់ហេតុ នៅក្នុងកាលៈទេសៈដែលលក្ខណៈនៃការព្រមព្រៀងមិនមានការប្រែប្រួលចាប់តាំងពីពេលការខ្វែងយោបល់គ្នាត្រូវបានចុះនៅក្នុងកំណត់ហេតុមក នឹងធ្វើឱ្យខូចដល់កម្មវត្ថុ និងគោលបំណងនៃវិធាននៃច្បាប់លក្ខន្តិកៈរបស់ អវតក ដូចដែលបានរៀបរាប់នៅក្នុងផ្នែកទី៥(ខ)(២)ខាងលើ ។

**៥(គ). តាមរបៀបផ្សេង បើសិនជាអង្គបុរេជំនុំជម្រះពិចារណាអំពីការផ្ទេរអំណាច ឬធ្វើកំណត់ហេតុចំពោះការខ្វែងយោបល់គ្នា ថាជាកាតព្វកិច្ចត្រូវដាក់ដោយមិនចំណុះគ្នាក៏ដោយ ក៏ ស.ច.ស មានការភាន់ច្រឡំនៅក្នុងការបដិសេធលើសំណើសុំដែរ**

៣៨. ក្នុងករណីដែលថា អបជ ពិចារណាពីការផ្ទេរអំណាច ឬការធ្វើកំណត់ហេតុនៃការខ្វែងយោបល់គ្នាជាលក្ខខណ្ឌតម្រូវបច្ចេកទេស ដើម្បីឱ្យសហព្រះរាជអាជ្ញាអន្តរជាតិ ដាក់សំណើដោយឡែកនីមួយៗ នោះសហព្រះរាជអាជ្ញាអន្តរជាតិដាក់អំណះអំណាងផ្សេងពីនេះថា ស.ច.ស មានការភាន់ច្រឡំនៅក្នុងការបដិសេធចោលសំណើទាំងនោះ ។

***(១) ស.ច.ស បានខកខានក្នុងការគិតគូរអំពីគោលការណ៍ជាមូលដ្ឋាននៃវិធាន២១***

៣៩. វិធាន២១ ក៏ចែងផងដែរថា នៅគ្រប់កាលៈទេសៈទាំងអស់ ភាពត្រឹមត្រូវ តម្លាភាព និង ប្រាកដប្រជាខាងផ្លូវច្បាប់នៃ កិច្ចដំណើរការនីតិវិធីទាំងអស់ ត្រូវតែយកចិត្តទុកដាក់ ។ វិធាន២១ ក៏ផ្តល់អាណត្តិដែលថា "តុល្យភាពក្នុងចំណោមសិទ្ធិរបស់គូភាគី" រាប់បញ្ចូលទាំងសិទ្ធិ សហព្រះរាជអាជ្ញា និងជនរងគ្រោះផង គួរតែត្រូវបានថែរក្សា ។

៤០. វិធាន២ គួសបញ្ជាក់ពីសារសំខាន់ជាអាទិភាពទៅលើវិធាន២១ ។ វិធាន២ ចែងថា "ប្រសិនបើមានបញ្ហាណាមួយកើតមានឡើង ដែលមិនមានចែងនៅក្នុងវិធានផ្ទៃក្នុងនេះ សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ ត្រូវធ្វើការសម្រេចចិត្ត ដោយស្របទៅលើមាត្រា១២(១) នៃកិច្ចព្រមព្រៀង និងមាត្រា២០ថ្មី, មាត្រា២៣ថ្មី, មាត្រា៣៣ថ្មី ឬ មាត្រា៣៧ថ្មី នៃច្បាប់ អ.វ.ត.ក ជាធរមាន *និងដោយផ្តោតការចិត្តទុកដាក់ជាពិសេស ទៅលើគោលការណ៍ជាមូលដ្ឋានដែលមានចែងក្នុងវិធាន២១ នៃវិធានផ្ទៃក្នុងនេះ*"[36] [សង្កត់ន័យត្រង់អក្សរទ្រេត] ។

[36] វិធាន ២ ។

៤១. អបជ ក៏បានទទួលស្គាល់ពីភាពចាំបាច់ដែលត្រូវគិតគូរទៅលើវិធាន២១ នៅលើគ្រប់ការធ្វើសេចក្តីសម្រេចទាំងអស់ ។ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនចុះខែកញ្ញា ឆ្នាំ២០១០ អបជ បានសម្រេចថា នៅពេលត្រូវពិចារណាថាតើត្រូវផ្តល់ការអនុញ្ញាតទៅតាមសំណើសុំបំពេញកិច្ចស៊ើបសួរឬអត់ វាជា *"កាតព្វកិច្ចទាំងរបស់សហចៅក្រមស៊ើបអង្កេត និងទាំងរបស់អង្គបុរេជំនុំជម្រះ ដែលត្រូវពិចារណាទៅលើគោលការណ៍ជាមូលដ្ឋានដែលបានកំណត់នៅក្នុងវិធាន២១"*[37] [សង្កត់ន័យត្រង់អក្សរទ្រេត]។

៤២. ជាងនេះទៀត អបជ បានទទួលស្គាល់ថា អនុលោមតាមវិធាន២១ ខ្លួនមាន "ភារកិច្ចធានាថា កិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ត្រឹមត្រូវយុត្តិធម៌"[38] ។ អបជ បានសម្រេចថា ការណ៍នេះ មួយផ្នែកមានការពាក់ព័ន្ធនឹងការប្រព្រឹត្តចំពោះបុគ្គលគ្រប់រូបដោយស្មើៗគ្នានៅចំពោះមុខតុលាការ និងការបកស្រាយច្បាប់តែងតែដើម្បី "ការពារផលប្រយោជន៍ទាំងអស់" របស់ភាគីដែលពាក់ព័ន្ធ[39] ។

៤៣. សហព្រះរាជអាជ្ញាអន្តរជាតិសន្និដ្ឋានថា ដីកាសម្រេចដែលកំពុងតវ៉ានេះ មិនបានគោរពឱ្យបានសមស្របទៅលើវិធាន២១ សម្រាប់ការពិចារណាអំពីភាពត្រឹមត្រូវយុត្តិធម៌ តម្លាភាព និងភាពប្រាកដប្រជាខាងផ្លូវច្បាប់ ឬផលប្រយោជន៍របស់ភាគីទេ ។

<u>*ភាពត្រឹមត្រូវយុត្តិធម៌ តម្លាភាព និងភាពប្រាកដប្រជាខាងផ្លូវច្បាប់*</u>

៤៤. ការបដិសេធលើសំណើសុំដោយ ស.ច.ស គឺជាការឆ្លើយតបមួយមិនសមស្របដោយសារតែប្រភេទនៃកង្វះខាតខាងបច្ចេកទេសដែលគេបានអះអាង និងការពិតដែលថា កង្វះខាតណាមួយដូច្នេះនឹងមិនធ្វើឱ្យមានការប៉ះពាល់ជាសារធាតុទៅលើកិច្ចដំណើរការនីតិវិធី ។ គួរឱ្យអស់សំណើច ដែលទាំងសហព្រះរាជអាជ្ញា និងទាំង ស.ច.ស មានការយល់ស្របគ្នាថាការផ្ទេរអំណាចក្រោមវិធាន១៣(៣) និងការធ្វើកំណត់ហេតុនៃការខ្វែងយោបល់គ្នាតាមវិធាន៧១(១)គឺគ្រាន់តែជាបែបបទប៉ុណ្ណោះ ។ នៅក្នុងដីកាសម្រេចរបស់ខ្លួនដែលកំពង់តវ៉ានេះ ស.ច.ស បានទទួលស្គាល់ពីសារសំខាន់នៃនីតិវិធីអំពីលក្ខខណ្ឌតម្រូវទាំងនេះ[40] ។ ជាពិសេស ស.ច.ស បានសម្រេចថាដើម្បីផ្ទេរអំណាចស្របតាមវិធាន ១៣(៣) ឬ ដើម្បីធ្វើកំណត់ហេតុនៃការខ្វែងយោបល់គ្នាស្របតាមវិធាន៧១(១) "វាជាបញ្ហានៃ

---

[37] សាលដីកាស្តីពីការពិចារណាឡើងវិញ ទៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតទៅលើសំណើសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង, ២៧ កញ្ញា ២០១០, D365/2/17, កថាខ័ណ្ឌទី៤៧ ។

[38] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ស្តីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី, ២៤ មិថុនា ២០១១, D411/3/6, កថាខ័ណ្ឌទី៣៥ ។

[39] *ក្នុងឯកសារដែលដូចខាងលើ*, កថាខ័ណ្ឌទី៣៥ ។

[40] ដីកាដែលកំពុងតវ៉ា, កថាខណ្ឌទី១១ ។

កំណាត់ហេតុ”[41] ។ លើសពីនេះ ស.ច.ស បានកត់សំគាល់ថា ការខ្វែងយោបល់គ្នាត្រូវធ្វើកំណត់ហេតុ ប៉ុន្តែគ្មានកាតព្វកិច្ចដែលត្រូវនាំយកការខ្វែងយោបល់គ្នាទៅចំពោះមុខ អបជ ទេ[42] ។

៤៥. ជំនួសឲ្យការបដិសេធលើសំណើសុំ វាជាការសមស្របជាង និងត្រឹមត្រូវយុត្តិធម៌ជាង ប្រសិនបើ ស.ច.ស បានធ្វើការបកស្រាយក្នុងលក្ខណៈមួយទូលំទូលាយលើវិធានទាំងនេះ ដើម្បីសម្រេចបាននូវទិសដៅ និងគោលបំណងរបស់តុលាការនេះ ឬធ្វើខ្លួនឲ្យមានតម្លាភាពជាង ចំពោះការបកស្រាយរបស់ខ្លួនទៅលើវិធាននានានៅក្នុងដីកាសម្រេចលើកទីមួយរបស់ខ្លួន ដែលនោះប្រហែលជាបានផ្តល់ឱកាសឲ្យសហព្រះរាជអាជ្ញាអន្តរជាតិ ដោះស្រាយបានចំពោះកង្វះខាតទាំងនោះរួចទៅហើយ ។

៤៦. អបជ បានបំភ្លឺថា ក្នុងកាលៈទេសៈជាក់លាក់ខ្លះ វិធាន២១ អាចយកធ្វើជាយុត្តិកម្មបាននៅក្នុងការបកស្រាយវិធាននានាឲ្យបានទូលំទូលាយ[43] ។ អបជ បានថ្លែងថា វាជាការសមស្របអាចធ្វើដូច្នេះបាន ប្រសិនបើមានបញ្ហាធ្ងន់ធ្ងរទាក់ទិននឹង “ភាពត្រឹមត្រូវយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីដូចមានចែងក្នុងវិធាន២១(១)(ក)”[44] និងថា ជាការចាំបាច់ដែលត្រូវសម្រេចទៅតាមមូលដ្ឋាននៃករណីនីមួយៗ ដោយ “ឈរលើតុល្យភាព ថាតើ ‘អង្គហេតុ និង កាលៈទេសៈ’ នៃបណ្តឹងឧទ្ធរណ៍ តម្រូវឲ្យមានការបកស្រាយទូលំទូលាយដែរឬអត់”[45] ។ នៅខណៈរហូតមកទល់ពេលនេះ វិធាន២១ មានការពាក់ព័ន្ធតែជាមួយ អបជ ដែលប្រើដើម្បីពង្រីកឲ្យបានទូលំទូលាយចំពោះសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍របស់ជនត្រូវចោទក៏ដោយ ក៏គោលការណ៍នៃភាពត្រឹមត្រូវយុត្តិធម៌ផ្នែកនីតិវិធីនេះ ដូចបានបញ្ជាក់យ៉ាងក្នុងសេចក្តីសម្រេចទាំងនេះ អាចត្រូវបានអនុវត្តតាមដោយ ស.ច.ស សម្រាប់កាលៈទេសៈនេះ ដើម្បីបកស្រាយចំពោះសិទ្ធិរបស់សហព្រះរាជអាជ្ញាផងដែរ ដើម្បីផ្តល់សិទ្ធិអំណាចដល់សហព្រះរាជអាជ្ញា ធ្វើសកម្មភាពជាបុគ្គល[46] ។

---

[41] ដីកាដែលកំពុងតវ៉ា, កថាខណ្ឌទី១១ ។

[42] ដីកាដែលកំពុងតវ៉ា, កថាខណ្ឌទី១១ ។

[43] សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ១៥ កុម្ភៈ ២០១១, D427/3/15, ទំព័រទី៣២ (ដែលលើកយោង សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហ ចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហកម្មឧក្រិដ្ឋកម្មរួម (JCE), D97/15/9, កថាខ័ណ្ឌទី៣០-៣៤ និងសេចក្តីសម្រេចស្តីពីការ បំពានដំណើរការ, ១០ សីហា ២០១០, D246/2/6, កថាខ័ណ្ឌទី៣០) ។

[44] សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ១៥ កុម្ភៈ ២០១១, D427/2/15, ទំព័រទី៧១ ។

[45] *ក្នុងឯកសារដដែលដូចខាងលើ,* កថាខ័ណ្ឌទី៧៣ (ដែលលើកយោងសេចក្តីសម្រេចស្តីពីការបំពានដំណើរការ, ១០ សីហា ២០១០, D246/2/6, ERN 00543781-99, កថាខ័ណ្ឌទី១៤ និង សេចក្តីសម្រេចស្តីពីសហកម្មឧក្រិដ្ឋកម្មរួម, D97/15/9, ERN 00486521-89, កថាខ័ណ្ឌទី៣០ ។

[46] សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ១៥ កុម្ភៈ ២០១១, D427/3/15 ។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហកម្មឧក្រិដ្ឋកម្មរួម, D97/15/9 ។ និងសេចក្តីសម្រេចស្តីពីការបំពានដំណើរការ, ១០ សីហា ២០១០, D264/2/6 ។

៤៧. តាមរបៀបផ្សេងពីនេះ ស.ច.ស អាចគួរមានតម្លាភាពជាងនេះនៅក្នុងដីកាសម្រេចលើកទីមួយរបស់ខ្លួនអំពីការបកស្រាយលើវិធាននានាដែលនឹងផ្តល់ឱកាសឲ្យសហព្រះរាជអាជ្ញាអន្តរជាតិ ដោះស្រាយបានចំពោះមោឃភាពនៃនីតិវិធីនៅក្នុងសំណើដូចដែលគេយល់ឃើញនោះ ។ ដូចបានកត់សំគាល់ខាងលើ នៅក្នុងដីកាសម្រេចលើកទីមួយរបស់ខ្លួន ស.ច.ស បានដាក់សេចក្តីបញ្ជាក់ទៅលើភាពចាំបាច់ដើម្បីឲ្យ "ប្រាកដថា តើសហព្រះរាជអាជ្ញាជាតិ ត្រូវបានផ្តល់ឱកាសឲ្យប្រើប្រាស់សិទ្ធិរបស់គាត់នៅក្រោមវិធាន១៣(១) និង ៧១(១) ដែរឬទេ" ។ ប៉ុន្តែ នៅក្នុងដីកាសម្រេចដែលកំពុងតវ៉ានេះ ស.ច.ស មិនបានដាក់ទម្ងន់ណាមួយទៅលើការពិតដែលថា សហព្រះរាជអាជ្ញាជាតិ ការពិតត្រូវបានផ្តល់នូវឱកាសនេះ ហើយ[គាត់]បានសម្រេចដោយសេរីមិនធ្វើដូច្នេះ នោះទេ ។ ប្រសិនបើដីកាសម្រេចលើកទីមួយរបស់ ស.ច.ស បានបញ្ជាក់ច្បាស់លាស់ថា ដើម្បីឲ្យ ស.ច.ស លើកយកមកពិចារណាសំណើទាំងនេះ សហព្រះរាជអាជ្ញាត្រូវផ្ទេរអំណាច ស្របតាមវិធាន១៣(១) ឬធ្វើកំណត់ហេតុនៃការខ្វែងយោបល់គ្នា ស្របតាមវិធាន៧១(១) ម្ល៉េះសហព្រះរាជអាជ្ញាទទួលបានការជូនដំណឹង ហើយអាចចាត់វិធានការសមស្របនានា ដើម្បីដោះស្រាយកង្វះខាតខាងនីតិវិធីដូចដែលគេយល់ឃើញទាំងនោះរួចទៅហើយ ។ ការណ៍នេះ ក៏នឹងបានជួយបញ្ចៀសមិនចាំបាច់មានបណ្តឹងឧទ្ធរណ៍នេះផង និងការពន្យារពេលជាយថាហេតុចំពោះកិច្ចដំណើរការនីតិវិធីផង ។ ហើយម្ល៉េះ សហព្រះរាជអាជ្ញាអន្តរជាតិនឹងបានចាត់វិធានការជាជំហ៊ានៗ ដូច្នេះ ការណ៍នេះ គឺមានការគាំទ្រតាមរយៈការពិតដែលថា ទោះបីជា សហព្រះរាជអាជ្ញាមានការខ្វែងយោបល់គ្នាជាមួយ ស.ច.ស លើការបកស្រាយវិធានផ្ទៃក្នុងក៏ដោយ ក៏បានធ្វើកំណត់ហេតុនៃការខ្វែងយោបល់គ្នាចំនួនបួន នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១១ ដែរ ។

៤៨. ជាងនេះ ដូចបានពិនិត្យក្នុងផ្នែក ៥(ក)(ii) ខាងលើ ការបដិសេធលើសំណើទាំងនេះដោយ ស.ច.ស គឺបានប្រាស់ចាកពីទម្លាប់នៃការអនុវត្តលើកមុនៗនៅអ.វ.ត.ក រួមទាំងទម្លាប់នៃការអនុវត្តមុនៗរបស់ ស.ច.ស ខ្លួនឯងផងដែរ ។ ការធ្វើដូច្នេះ ស.ច.ស បានខកខានក្នុងការពិចារណាលើគោលការណ៍នៃភាពប្រាកដប្រជា និងអនុលោមភាពនៃច្បាប់ ដូចបានតម្កល់នៅក្នុងវិធាន២១ ។

៤៩. ជាចុងក្រោយ នៅក្នុងដីកាដែលកំពុងតវ៉ានេះ ស.ច.ស បានតម្រូវឲ្យសហព្រះរាជអាជ្ញាបញ្ជាក់ថា តើលក្ខខណ្ឌតម្រូវខាងផ្លូវច្បាប់នៃវិធាន១៣ ឬ៧១ បានចំពេញហើយឬនៅ ឬ "បង្ហាញឲ្យជឿបានថាមិនអាចបំពេញបាន"[47] ។ ដោយដាក់លក្ខខណ្ឌតម្រូវដូចបញ្ជាក់នៅខាងចុងឃ្លាខាងលើនេះ ស.ច.ស បានដាក់បន្ទុកបន្ថែមទៀតលើសហព្រះរាជអាជ្ញាថា គ្មានមូលដ្ឋានច្បាប់ ទាំងនៅក្នុងវិធាន១៣ និង ៧១ ទេ និងថាបើដូច្នេះ គេមិនអាចទាយទុកជាមុនបានឡើយ ។

<u>សិទ្ធិរបស់ភាគី</u>

[47] ដីកាដែលកំពុងតវ៉ា, កថាខណ្ឌទី៩ ។

៥០. ដីកាដែលកំពុងតវ៉ានេះ រំលោភលើសិទ្ធិរបស់សហព្រះរាជអាជ្ញា សិទ្ធិរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី និងសិទ្ធិរបស់ជនរងគ្រោះ ។

៥១. ចំពោះសហព្រះរាជអាជ្ញា ដីកាដែលកំពុងតវ៉ានេះជ្រៀតជ្រែកចូលក្នុងសិទ្ធិរបស់សហព្រះរាជអាជ្ញាក្នុងការត្រួតត្រាលើនីតិវិធីផ្ទៃក្នុងរបស់ខ្លួន និងដើម្បីតាមដាន និងធានាថាកិច្ចស៊ើបសួរត្រូវបានអនុវត្តដោយត្រឹមត្រូវ ។ ការិយាល័យសហព្រះរាជអាជ្ញា គឺជាការិយាល័យឯករាជ្យមួយនៅ អ.វ.ត.ក[48] ។ ដោយការទទួលស្គាល់ចំពោះឯករាជ្យភាពរបស់ការិយាល័យនេះ វិធានផ្ទៃក្នុងបានចែងថា ការិយាល័យសហព្រះរាជអាជ្ញាមានសិទ្ធិតាមច្បាប់ក្នុងការត្រួតត្រាលើកិច្ចការផ្ទៃក្នុងរបស់ខ្លួនផ្ទាល់ ។ ជាពិសេស វិធាន១៣.២ នៃវិធានផ្ទៃក្នុង ផ្តល់អំណាចដល់សហព្រះរាជអាជ្ញាក្នុងការអនុម័ត និងយល់ព្រមលើបទបញ្ជារដ្ឋបាលសម្រាប់ការិយាល័យរបស់ខ្លួន បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយការិយាល័យនានារបស់តុលាការ និងការិយាល័យរដ្ឋបាល លើបញ្ហាដែលអាចនឹងមានការប៉ះពាល់ដល់ពួកគេ[49] ។ វិធាន១៣.៦ ចែងថា សេចក្តីសំរេចរបស់សហព្រះរាជអាជ្ញាមិនអាចប្តឹងឧទ្ធរណ៍បានឡើយ[50] ។ ទន្ទឹមនេះ ថាតើត្រូវផ្ទេរអំណាច ឬ ធ្វើកំណត់ហេតុនៃការខ្វែងយោបល់គ្នា គឺជាកិច្ចការផ្ទៃក្នុងដែលត្រូវកំណត់សម្រេចដោយសហព្រះរាជអាជ្ញាម្នាក់ៗ ដែលមិនគួរជ្រៀតជ្រែកតាមរយៈលំដាប់នៃកិច្ចស៊ើបសួរឡើយ ដរាបណាសហព្រះរាជអាជ្ញាម្នាក់ៗ ត្រូវបានផ្តល់ឱកាសក្នុងការប្រើប្រាស់នូវសិទ្ធិរបស់ខ្លួនស្របតាមវិធាន១៣(៣) និង៧១(១) ។

៥២. ជាការបន្ថែម តាមវិធាន៥៥(១) និង៦៦(១) គឺជាសិទ្ធិជាមូលដ្ឋានរបស់សហព្រះរាជអាជ្ញាដែលត្រូវតាមដានទៅលើកិច្ចស៊ើបសួរ រួមមានទាំង ការដាក់សំណើសុំបំពេញកិច្ចស៊ើបសួរបន្ទាប់ពីការបិទកិច្ចស៊ើបសួរ[51] ។ ការតាមដាននេះ ធ្វើឱ្យកាន់តែមានភាពចាំបាច់ថែមទៀតដោយសារថាសហព្រះរាជអាជ្ញា (ឬសហព្រះរាជអាជ្ញាអន្តរជាតិនៅក្នុងសំណុំរឿងលេខ០០៣នេះ) ច្បាស់ណាស់ គឺជាអាជ្ញាធរដែលប្តឹងទៅ សហចៅក្រមស៊ើបអង្កេត អំពីអង្គហេតុនានាជាបទព្រហ្មទណ្ឌ ហើយហេតុនេះ វិសាលភាពនៃកិច្ចស៊ើបសួរដែលត្រូវតែដឹកនាំធ្វើជាចាំបាច់ខានមិនបាន ។ សហព្រះរាជអាជ្ញា ក្នុងនាមជាភាគីអ្នកផ្តួចផ្តើមគំនិត មានសិទ្ធិ និង កាតព្វកិច្ចដើម្បីធានាធ្វើឱ្យប្រាកដថាតួនាទីភារកិច្ចដែលបានប្រគល់ទៅឱ្យសហចៅក្រមស៊ើបអង្កេត ត្រូវបានបំពេញហើយកិច្ចស៊ើបសួរត្រូវបានដឹកនាំធ្វើដោយត្រឹមត្រូវ និងបានបំពេញចប់សព្វគ្រប់ ។

៥៣. បន្ថែមពីលើនេះ វិធាន២១.១ នៃវិធានផ្ទៃក្នុង(ក) តម្រូវឱ្យដំណើការនីតិវិធីទាំងឡាយរបស់ អវតក ត្រូវតែ "ធានាឱ្យមានការបំបែកចេញដាច់ដោយឡែកពីគ្នា រវាងសមត្ថកិច្ចដែលទទួលខុសត្រូវក្នុងការចោទប្រកាន់ និងសមត្ថកិច្ចដែលទទួលខុសត្រូវក្នុងការកាត់សេចក្តី" ។

---

[48] វិធាន១៣.១ ។

[49] វិធាន១៣.២ ។

[50] វិធាន១៣.៦ ។

[51] វិធាន៥៥.១០ នៃវិធានផ្ទៃក្នុង។ វិធាន៦៦.១ នៃវិធានផ្ទៃក្នុង។

៥៤. បទបញ្ញត្តិដូចជាវិធាន៥៦.១នៃវិធានផ្ទៃក្នុង បានប្រគល់ទៅឱ្យចៅក្រមនានានៃ អវតក នូវអំណាចក្នុងន័យបង្គប់ ក្នុងការអនុវត្តនូវភារកិច្ចនិងកាតព្វកិច្ចនានារបស់ភាគីដទៃៗទៀត ។ ប៉ុន្តែអំណាចទាំងនោះត្រូវតែបានអនុវត្តនៅក្នុងផលប្រយោជន៍ដើម្បីថែរក្សាការពារដល់សុច្ចរិតភាពនៃដំនោះរការនីតិវិធីនិងឱ្យបានស្របទៅតាមក្របខណ្ឌនៃច្បាប់ជាធរមាន ។

៥៥. ដោយចេញដីកាតាមរបៀបនេះ គឺ ស.ច.ស បានជ្រៀតជ្រែកចូលក្នុង កិច្ចការផ្ទៃក្នុងរបស់សហព្រះរាជអាជ្ញា និងបានរារាំងដល់សហព្រះរាជអាជ្ញាអន្តរជាតិ មិឱ្យបំពេញនូវកាតព្វផ្លូវច្បាប់របស់ខ្លួនក្នុងការត្រួតពិនិត្យទៅលើវិសាលភាព និងតាមឃ្លាំមើលកិច្ចស៊ើបសួរ ។

៥៦. ទាក់ទិននឹងជនរងគ្រោះ សិទ្ធិរបស់ពួកគេបានទទួលរងការប៉ះពាល់ជាពិសេស ដោយសារតែការបដិសេធលើសំណើសុំពន្យារពេលកំណត់សម្រាប់ដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ។

៥៧. ជនរងគ្រោះមានសិទ្ធិយ៉ាងទូលំទូលាយទាក់ទិននឹងកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក រួមទាំង ប៉ុន្តែមិនកម្រិតត្រឹមតែ សិទ្ធិទទួលបានការជូនដំណឹងប៉ុណ្ណោះទេ ។ សិទ្ធិទាំងនេះត្រូវបានតម្កល់ក្នុងវិធានផ្ទៃក្នុង[52] ហើយត្រូវបានទទួលស្គាល់ និងបានពង្រីកថែមទៀតដោយ អបជ[53] ។ ជាពិសេស វិធាន ២១ (១) (គ) តម្រូវឱ្យ អ.វ.ត.ក "ធានាថា ជនរងគ្រោះត្រូវទទួលបាន *ការជូនព័ត៌មាន* ហើយសិទ្ធិរបស់ជនរងគ្រោះ ត្រូវបានគោរព *នៅគ្រប់ដំណាក់កាលទាំងអស់* នៃកិច្ចដំណើរការនីតិវិធី"[54] ។ ជាការបន្ថែម វិធាន២១ ចែងថា ច្បាប់ អ.វ.ត.ក ទាំងអស់ រាប់ទាំងវិធានផ្ទៃក្នុង "*ត្រូវតែ* បកស្រាយក្នុងន័យ *ការពារជានិច្ចដល់ប្រយោជន៍* របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និង *ជនរងគ្រោះ*..."[55] [សង្កត់ន័យត្រង់អក្សរទ្រេត] ។

៥៨. សិទ្ធិនេះ គឺមានសារៈសំខាន់ខ្ពស់បំផុតក្នុងអម្លុងពលនៃដំណាក់កាលមុនការជំនុំជម្រះ ដោយហេតុថាសិទ្ធិក្នុងការទទួលបាននូវព័ត៌មានពាក់ព័ន្ធនឹងការស៊ើបសួរ គឺមានសារៈសំខាន់សម្រាប់ជនរងគ្រោះដើម្បីឱ្យបានក្លាយទៅជា ដើមបណ្តឹងរដ្ឋប្បវេណី ។ ដោយហេតុថាជនរងគ្រោះមិនត្រូវបានផ្តល់ព័ត៌មានឱ្យបានគ្រប់គ្រាន់ សហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងឋានៈជាអ្នកតំណាងម្នាក់ការពារផលប្រយោជន៍សាធារណជន មានករណីយកិច្ចតាមផ្លូវច្បាប់ និងផ្លូវសីលធម៌ បំពេញកិច្ចការក្នុងនាមជនរងគ្រោះ ក្នុងគោលបំណងដើម្បីការពារសិទ្ធិរបស់ជនរងគ្រោះ ។

---

[52] *សូមអានផងដែរ* វិធាន២១, ២៣, ២៣ *ស្ទួន* ។

[53] *សូមអានជាទូទៅ* សាលដីកាអំពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងរឿងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន, ២០ មីនា ២០០៨, C11/53, ERN 00172886-905 ។

[54] វិធាន២១(១)(គ) ។

[55] វិធាន២១(១) ។

៥៩. អបជ បានទទួលស្គាល់ថា ភាគីដើមបណ្តឹងរដ្ឋប្បវេណី ដូចភាគីទាំងអស់ដទៃទៀតនៃកិច្ចដំណើរការនីតិវិធីដែរ មានសិទ្ធិទទួលបាននូវភាពត្រឹមត្រូវយុត្តិធម៌ខាងផ្នែកនីតិវិធី[56] ។ អបជ បានកំណត់និយមន័យនៃឃ្លា ភាពត្រឹមត្រូវយុត្តិធម៌ផ្នែកនីតិវិធី យ៉ាងដូច្នេះថា "ជានីតិវិធីដែលមានសិទ្ធិអំណាច និងមានតម្លាភាពមួយដែលផ្តល់សិទ្ធិ និងកាតព្វកិច្ចយ៉ាងត្រឹមត្រូវ ច្បាស់លាស់ឆាប់រហ័ស និងអនុវត្តបាន ។ ក្នុងមធ្យោបាយនេះ គេមានភាពប្រាកដប្រជាដោយមានការរំពឹងទុកថា បញ្ហាមួយអាចនឹងត្រូវបានដោះស្រាយយ៉ាងត្រឹមត្រូវ និងទៅតាមការកំណត់ ក្នុងរបៀបមួយដែលគេអាចទាយទុកជាមុនបាន"[57] ។ ការធានាចំពោះដំណើរការសមស្របត្រូវតែមានវិសាលភាព រាប់បញ្ចូលទាំងការផ្តល់ព័ត៌មានពាក់ព័ន្ធនឹងវិសាលភាពនៃកិច្ចស៊ើបសួរ ដោយផ្តល់លទ្ធភាពដល់ជនរងគ្រោះក្នុងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគាត់ទាន់ពេលវេលា និងស្របតាមលក្ខខណ្ឌតម្រូវនានាដូចមានចែងក្នុងវិធានផ្ទៃក្នុង[58] ។

៦០. ជាងនេះទៀត អបជ បានសម្រេចថា អនុលោមតាមវិធាន២១ ស.ច.ស ត្រូវមានកាតព្វកិច្ចបង្ហាញឱ្យឃើញនូវការប្រុងប្រយ័ត្នសមស្រប ទាក់ទងនឹងសេចក្តីសម្រេចដែលមានការជាប់ជំពាក់ទៅនឹងសិទ្ធិរបស់ជនរងគ្រោះ[59] ។ ជាពិសេស ទោះបីជាមានការទទួលស្គាល់ថា វិធាននានាបានដាក់អាណត្តិឱ្យមានការកម្រិតមួយចំពោះភាពសម្ងាត់ទាក់ទិននឹងកិច្ចស៊ើបសួររបស់ ក.ស.ច.ស យ៉ាងណាក្តី ក៏ អបជ បានសម្រេចថា បទប្បញ្ញត្តិស្តីពីភាពសម្ងាត់ គួរត្រូវបានអានរួមជាមួយនឹងបទប្បញ្ញត្តិនានាស្តីពីគោលការណ៍នីតិវិធីជាមូលដ្ឋានទៅគ្រប់ពេលទាំងអស់នៅចំពោះមុខ អ.វ.ត.ក ដែលតម្រូវថា "ជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ហើយសិទ្ធិរបស់ជនរងគ្រោះ ត្រូវបានគោរព *នៅគ្រប់ដំណាក់កាលទាំងអស់* នៃកិច្ចដំណើរការនីតិវិធី" ។ អបជ បានសម្រេចជាបន្តទៀតថា "វិធាន២១(១)(គ) មិនបានទុកឱ្យមានកន្លែងទំនេរសម្រាប់ការបកស្រាយឡើយ" [សង្កត់ន័យដោយពាក្យដើម][60] ។

៦១. សិទ្ធិទទួលបានការជូនព័ត៌មាន គឺជារឿងសំខាន់បំផុតដើម្បីឱ្យជនរងគ្រោះ ប្រើប្រាស់សិទ្ធិរបស់ពួកគាត់ ។ តាមវិធានផ្ទៃក្នុង ដើម្បីឱ្យទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណី ជននោះត្រូវបង្ហាញឱ្យឃើញ

---

[56] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ និងដីកាសម្រេចចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ លើការទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី, ២៧ មេសា ២០១០, D274/4/5, កថាខ័ណ្ឌទី១៣ ។

[57] *ក្នុងឯកសារដែលដូចខាងលើ,* កថាខ័ណ្ឌទី១៣ ។

[58] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទិននឹងសំណុំរឿងលេខ ០០៣, ២៥ ឧសភា ២០១១, D14/1/1, កថាខ័ណ្ឌទី៥២ ។

[59] សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី, ២៤ មិថុនា ២០១១, D411/3/6, កថាខ័ណ្ឌទី៥៤ ។

[60] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេត ស្តីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី, ២៤ មិថុនា ២០១១, D411/3/6, កថាខ័ណ្ឌទី៥២ ។

ថា ខ្លួនពិតជាបានទទួលរងគ្រោះថ្នាក់ខាងផ្លូវកាយ ផ្លូវចិត្ត ឬ សតិបញ្ញា ដែលនេះ គឺជាផលវិបាក ដោយផ្ទាល់ពីឧក្រិដ្ឋកម្មយ៉ាងហោចណាស់មួយ ក្នុងចំណោមឧក្រិដ្ឋកម្មនានាដែលបាន និងកំពុងស៊ើប អង្កេត[61] ។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ "ត្រូវតែផ្ដល់សេចក្ដីលម្អិតអំពីស្ថាន ភាពរបស់ជនរងគ្រោះ បញ្ជាក់ពីឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ និងត្រូវភ្ជាប់មកជាមួយនូវភស្ដុតាង ណាមួយពីគ្រោះថ្នាក់ដែលខ្លួនទទួលរង ឬដែលមានទំនោរបង្ហាញឱ្យឃើញពីពិរុទ្ធភាពរបស់ចារីដែល បានចោទប្រកាន់"[62] ។

៦២. អបជ ក៏បានកត់សំគាល់ផងដែរថា សិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានការជូនដំណឹង នៅគ្រប់ ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី ជាការសំខាន់យ៉ាងពិសេស ពីព្រោះមិនដូចមេធាវីការ ពារក្ដីដែលជាភាគីនៃកិច្ចដំណើរការនីតិវិធីទេ អ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះមិនមានសិទ្ធិ ដោយស្វ័យប្រវត្តិក្នុងការពិនិត្យមើលសំណុំរឿងឡើយ ដែលនេះធ្វើឱ្យពួកគាត់ពឹងផ្អែកទាំងស្រុងទៅ លើព័ត៌មានដែលពួកគាត់ទទួលបានពី ស.ច.ស[63] ។ លើសពីនេះ អបជ បានកត់សំគាល់ថា ដូចដែល សេចក្ដីសម្រេច ស្ដីពីភាពអាចទទួលយកបាននៃដើមបណ្ដឹងរដ្ឋប្បវេណី គឺស្ថិតនៅតែក្នុងយុត្តាធិការ របស់ ស.ច.ស តែមួយប៉ុណ្ណោះដោយបណ្ដឹងឧទ្ធរណ៍ត្រូវធ្វើទៅកាន់ អបជ វាមិនស្ថិតក្នុងយុត្តាធិការ របស់អង្គជំនុំជម្រះសាលាដំបូង មិនដូចគ្នាកាលពីអតីតកាលទេ ។ ភាពចាំបាច់ក្នុងការទទួលបាននូវ ព័ត៌មានដែលត្រឹមត្រូវ និងទាន់ពេលវេលាដោយជនរងគ្រោះ នៅគ្រប់ដំណាក់កាលទាំងអស់នៅមុន សវនាការជំនុំជម្រះ គឺជា "ការសំខាន់ដែលមានលក្ខណៈចាប់បង្ខំជាងពេលមុនៗ"[64] ។

៦៣. ពាក់ព័ន្ធនឹងសំណុំរឿង ០០៣ ជនរងគ្រោះមិនត្រូវបានគេជូនព័ត៌មានឱ្យបានត្រឹមត្រូវទេ ។ នៅក្នុង សំណុំរឿងលេខ ០០២ ដោយអនុលោមតាមវិធាន៥៦(២) ស.ច.ស បានចេញសេចក្ដីជូនដំណឹងជា សាធារណៈមួយ ស្ដីពីទីតាំង និងព្រឹត្តការណ៍ឧក្រិដ្ឋកម្មនានាដែលស្ថិតនៅក្រោមកិច្ចស៊ើបសួរ នៅមុន ពេលបិទការស៊ើបសួរ[65] ចំណែកក្នុងសំណុំរឿងលេខ ០០៣ វិញ គ្មានសកម្មភាពបែបនេះត្រូវបានគេ ធ្វើឡើងឡើយ[66] ។

---

[61] វិធាន២៣ *ស្ទួន* ១ ។

[62] វិធាន២៣ *ស្ទួន* ៤ ។

[63] សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេត ស្ដីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី, ២៤ មិថុនា ២០១១, D411/3/6, កថាខណ្ឌទី៥២ ។

[64] សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេត ស្ដីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី, ២៤ មិថុនា ២០១១, D411/3/6, កថាខណ្ឌទី៥៣ ។

[65] សេចក្ដីថ្លែងការណ៍ចេញពីសហចៅក្រមស៊ើបអង្កេត, កិច្ចស៊ើបសួរសំណុំរឿងលេខ ០០២/១៩-០៩-២០០៧ អវតក/កសចស និងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី, ៥ ធ្នូ ២០០៩,អាចរកបាននៅក្នុងវិបសាយរបស់អវតក ។

[66] សំណើបំពេញកិច្ចស៊ើបសួរលើកទីមួយ, កថាខណ្ឌទី១៩ ។

៦៤. សេចក្ដីជូនដំណឹងស្ដីពីការបិទការស៊ើបសួរ បានបញ្ចេះឱ្យមានការកំណត់ពេលចំនួន១៥ ថ្ងៃ សម្រាប់ជនរងគ្រោះដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី[67] ។ ប៉ុន្តែ មុនពេលមានសេចក្ដីជូនដំណឹងនេះ គ្មានព័ត៌មានសាធារណៈត្រូវបានផ្ដល់ជូនឡើយទាក់ទងនឹងវិសាលភាពនៃកិច្ចស៊ើបសួរ ។ គឺមានតែដីកាចាត់ឱ្យស៊ើបសួរជំនួសមួយគត់ត្រូវបានគេចាត់ថ្នាក់ថាលែងសម្ងាត់ ប៉ុន្តែមិនអាចឱ្យគេរកបានឡើយរហូតដល់ក្រោយបិទកិច្ចស៊ើបសួរ[68] ។

៦៥. ដោយសារតែកង្វះខាតព័ត៌មាននេះ មានពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីតែពីរប៉ុណ្ណោះ ត្រូវបានដាក់នៅមុនការចេញសេចក្ដីជូនដំណឹងស្ដីពីការបិទការស៊ើបសួរ ដោយពុំមានព័ត៌មានផ្លូវការណាមួយអំពីវិសាលភាពនៃកិច្ចស៊ើបសួរឡើយ ។ ផ្ទុយទៅវិញ សំណុំរឿងលេខ ០០៣ មានពាក្យសុំចំនួន 4,128[69] ។

៦៦. ដោយសារចំនួនពាក្យសុំនៅមានកម្រិតដូច្នេះ សហព្រះរាជអាជ្ញាអន្តរជាតិ ពីដំបូងបានដាក់បង្ហាញឱ្យឃើញនូវសេចក្ដីសង្ខេបមួយ អំពីព័ត៌មានដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ក្នុងសេចក្ដីប្រកាសព័ត៌មានមួយ បន្ទាប់មកក៏បានដាក់ជូនសំណើសុំពន្យារពេលកំណត់ សម្រាប់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី[70] ។ ស.ច.ស បានឆ្លើយតប តាមរយៈសេចក្ដីប្រកាសព័ត៌មានមួយ ដោយបានធ្វើការពន្យារពេលបីសប្ដាហ៍[71] ។ ទោះជាយ៉ាងនេះក្ដី ជនរងគ្រោះមិនត្រូវបានជូនគេដំណឹងអំពីការពន្យារនេះជាមុនឡើយ ជាលទ្ធផល ភាគីដើមបណ្ដឹងរដ្ឋប្បវេណីសក្ដានុពលនានាបានដឹងអំពីការពន្យារនេះ តែនៅថ្ងៃដែលសេចក្ដីប្រកាសព័ត៌មានត្រូវបានចេញតែប៉ុណ្ណោះ ដែលមានរយៈពេលតែមួយថ្ងៃនៅមុនថ្ងៃផុតកំណត់នៃពេលវេលាដែលបានពន្យារ ។ ការណ៍នេះគឺមានតម្លៃស្មើនឹងការរំលោភសិទ្ធិរបស់ជនរងគ្រោះ ។

### *(២) ការខកខានរបស់ ស.ច.ស មិនបានពិចារណាលើសំណើ គឺជាការបំពាននឹងកាតព្វកិច្ចផ្លូវច្បាប់ របស់ ស.ច.ស ដែលត្រូវដឹកនាំបំពេញកិច្ចស៊ើបសួរឱ្យបានចប់សព្វគ្រប់ និងមិនលំអៀង*

៦៧. កិច្ចស៊ើបសួរណាមួយគឺមានលក្ខណៈជាការបង្ខំត្រូវតែធ្វើចំពោះឧក្រិដ្ឋកម្មទាំងឡាយ ដែលស្ថិតនៅក្នុងរង្វង់យុត្តាធិការរបស់ អវតក[72] ។ សហចៅក្រមស៊ើបអង្កេតត្រូវបានច្បាប់តម្រូវឱ្យត្រូវតែ

[67] សេចក្ដីជូនដំណឹងស្ដីពីការបិទការស៊ើបសួរ, ២៩ មេសា ២០១១, D13 ។

[68] សំណើបំពេញកិច្ចស៊ើបសួរលើកទីមួយ, កថាខ័ណ្ឌទី៣, ១៤ ។

[69] សំណុំរឿងលេខ ០០២, ដីកាដំណោះស្រាយ, ១៥ កញ្ញា ២០១០, ERN 00604508-5247, D427, កថាខ័ណ្ឌទី១០ ។

[70] សំណើសុំពន្យារពេលកំណត់ ។

[71] សេចក្ដីប្រកាសព័ត៌មាន, សេចក្ដីថ្លែងការណ៍ចេញពីសហចៅក្រមស៊ើបអង្កេត ទាក់ទិននឹងសំណើសុំរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងសំណុំរឿងលេខ ០០៣, ៧ មិថុនា ២០១១, កថាខ័ណ្ឌទី៤ ។

[72] វិធាន៥៥.១ ។

បំពេញកិច្ចស៊ើបសួរណាមួយឬទាំងអស់ ដែលនាំមកនូវការបង្ហាញការពិត[73] ។ ក្នុងករណីណាក៏ដោយ សហចៅក្រមស៊ើបអង្កេតត្រូវតែដឹកនាំការស៊ើបសួរដោយគ្មានភាពលំអៀង[74] ។

៦៨. ជាងនេះទៅទៀត សហចៅក្រមស៊ើបអង្កេតត្រូវមានភារកិច្ចមួយក្នុងការ ជូនដំណឹងដល់សហព្រះរាជអាជ្ញា នៅពេលណាដែលរកឃើញថាមានអង្គហេតុថ្មីៗនៅក្នុងពេលស៊ើបអង្កេត[75]។ សហចៅក្រមស៊ើបអង្កេត ក៏តម្រូវឱ្យធ្វើការពិនិត្យពិចារណាលើរាល់សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរដែលធ្វើឡើងដោយ សហព្រះរាជអាជ្ញា និងដោយភាគីផ្សេងៗទៀត ។ បើសិនជា សហចៅក្រមស៊ើបអង្កេត មិនយល់ព្រមលើសំណើសុំទេនោះ ត្រូវចេញដីកាសំអាងហេតុមួយឱ្យបានយ៉ាងឆាប់បំផុតតាមដែលអាចធ្វើទៅបាន[76] ។

៦៩. ដូចដែលបានលើកឡើងនៅក្នុងកថាខណ្ឌទី៣ និងទី៤ ខាងលើ សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែមទាំងបីនេះ មានសារៈសំខាន់ជាសារវន្ត ដោយសារសហព្រះរាជអាជ្ញាអន្តរជាតិយល់ឃើញថា កិច្ចស៊ើបសួរបឋមរបស់សហចៅក្រមស៊ើបអង្កេត មិនទាន់បានបំពេញចប់សព្វគ្រប់ ។ ការពិនិត្យមើលឡើងវិញមួយទៅលើសំណុំរឿងស៊ើបអង្កេតបង្ហាញឱ្យឃើញថា នៅក្នុងអម្លុងពេលជាងម្ភៃខែ សហចៅក្រមស៊ើបអង្កេតបានដឹកនាំធ្វើសម្ភាសន៍សាក្សីសរុបបានចំនួនតែ២០លើកប៉ុណ្ណោះ ។ ផ្ទុយពីសំណុំរឿងលេខ០០២ ដែលសហចៅក្រមស៊ើបអង្កេតបានដឹកនាំធ្វើសម្ភាសន៍សាក្សីចំនួនជាង៨០០នាក់ឯណោះ[77] ។ លើសពីនេះ ជនសង្ស័យមិនត្រូវបានគេប្រាប់ឱ្យដឹងថាពួកគេកំពុងតែស្ថិតនៅក្នុងការស៊ើបសួរ ឬមួយក៏ត្រូវបានផ្តល់ឱកាសណាមួយដើម្បីឱ្យផ្តល់ភស្តុតាងនោះឡើយ ទោះបីជាដោយសារថាពួកគេមានការជាប់ជំពាក់នៅក្នុងភស្តុតាងជាឯកសារ និងទាំងនៅក្នុងភស្តុតាងជាសក្ខីកម្មផងនោះក៏ដោយ[78] ។

៧០. ជាងនេះទៅទៀត ព័ត៌មានដែលទាក់ទងនឹងការស៊ើបសួរគឺត្រូវបានបង្ហាញឱ្យតែសហព្រះរាជអាជ្ញាដឹង តែប៉ុណ្ណោះនៅក្នុងចន្លោះរវាងថ្ងៃទី១០ខែមីនា និង ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១១ ក្នុងរយៈពេលដ៏ខ្លីមុនការចេញសេចក្តីជូនដំណឹងអំពីសេចក្តីសន្និដ្ឋានបិទកិច្ចស៊ើបសួរ កាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១។ ដីកាចាត់ឱ្យស៊ើបសួរជំនួសតែមួយគត់ដែលបានចេញនៅក្នុងសំណុំរឿងនេះគឺត្រូវបានប្រកាសថា លែងជាការសំងាត់ កាលពីក្នុងខែឧសភា ឆ្នាំ២០១១ ។ ការមិនមានការបង្ហាញឱ្យដឹងពីភស្តុតាងដែលប្រមូលបាននៅមុនខែមីនា ឆ្នាំ២០១១បានធ្វើឱ្យសហព្រះរាជអាជ្ញាអន្តរជាតិមិនអាចមានលទ្ធភាពក្នុងការតាមឃ្លាំមើលកិច្ចសើបសួរបានប្រកបដោយប្រសិទ្ធភាពឡើ

---

73 វិធាន៥៥.៥ ។

74 វិធាន៥៥.៥ ។

75 វិធាន៥៥.៣ ។

76 វិធាន៥៥.១០ ។

77 សំណើសុំកិច្ចស៊ើបសួរ លើកទីមួយ, កថាខណ្ឌទី១០ ។

78 សំណើសុំកិច្ចស៊ើបសួរ លើកទីមួយ, កថាខណ្ឌទី៣ ។

យ ។ ជាលទ្ធផល គឺបណ្ដាលឱ្យសហព្រះរាជអាជ្ញាអន្តរជាតិ មិនអាចដាក់សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរនានាដែលពាក់ព័ន្ធបានឡើយ រហូតទាល់តែដល់ពេលបន្ទាប់ពីការដាក់សេចក្ដីជូនដំណឹងអំពីសេចក្ដីសន្និដ្ឋានបិទកិច្ចស៊ើបសួរ[79] ។

៧១. សហព្រះរាជអាជ្ញាអន្តរជាតិ ជឿថាសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរទាំងបីរបស់ខ្លួន ដែលក្នុងនោះរួមមាន ក្នុងចំណោមអ្វីៗដទៃទៀតជាច្រើននូវ ៖ ការដាក់បន្ថែមឯកសារនៃសំណុំរឿងលេខ០០២មួយចំណួនទៅក្នុងសំណុំរឿងលេខ០០៣[80]។ ការកំណត់អត្តសញ្ញាណនិងធ្វើសម្ភាសន៍សាក្សីគន្លឹះដែលដឹងអំពីរឿងទាក់ទងនឹងប្រតិបត្តិការការងារ និងរចនាសម្ព័ន្ធនៃសិទ្ធអំណាចនៃមន្ទីរស-២២[81], មន្ទីរសន្តិសុខវត្តឥន្ទញាណ និងការដ្ឋានវាយថ្មដែលស្ថិតនៅជិតស្ទឹងហាវ[82] ។ និងកំណត់អំពីតួនាទីរបស់ជនសង្ស័យឈ្មោះ ស៊ូ ម៉េត[83] និងមាស មុត[84] នៅក្នុងឧក្រិដ្ឋកម្មទាំងឡាយដែលបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ គឺមានសារសំខាន់ជាសារវន្តដើម្បីបំពេញកិច្ចស៊ើសួរឱ្យបានចប់សព្វគ្រប់ ។

៧២. ការដែលមិនមានធ្វើកិច្ចស៊ើបសួរឱ្យបានពេញលេញ បណ្ដាលឱ្យមិនមានលទ្ធភាពអាចមានភស្តុតាងគ្រប់គ្រាន់ដើម្បីធ្វើសេចក្ដីសំរេចលើបញ្ហាសំខាន់ៗមួយចំនួនដែលរួមមាន តែមិនកំរិតត្រឹមប៉ុណ្ណោះនោះទេ អំពីថាតើ អវតក មានយុត្តាធិការបុគ្គលទៅលើជនសង្ស័យទាំងពីររូបដូចដែលមានឈ្មោះខាងលើដែរឬទេ?[85] ។

៧៣. ដោយហេតុថា អបជ បានសម្រេចថា បញ្ហាយុត្តាធិការ គឺជាមូលដ្ឋានគ្រឹះ[86] នោះបើគ្មានកិច្ចស៊ើបសួរបន្ថែមទេ លទ្ធភាពក្នុងកំរិតខ្ពស់មួយអាចនឹងថា សំណុំរឿងលេខ ០០៣ ទាំងមូល នឹងត្រូវបានបដិសេធ ។ ដោយពិចារណាថា គេមានមូលហេតុឱ្យជឿបានថា ភស្តុតាងដ៏សម្បូរណ៍បែបដែលអាចភ្ជាប់ទៅជនសង្ស័យនានា អាចនឹងត្រូវស្វែងរកបាន[87] ។ ជាការសំខាន់ខានមិនបានដែលថា សំណើសុំបំពេញកិច្ចស៊ើបសួរទាំងបីរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ត្រូវតែបានអនុញ្ញាតក្នុងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនាពេលនេះ វាជាឱកាស (ដំបូង) និងជាឱកាសចុងក្រោយបង្អស់ សម្រាប់សហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីធ្វើឱ្យមានផលប៉ះពាល់មួយលើការប្រមូលភស្តុតាងនៃកិច្ចស៊ើប

---

[79] សំណើសុំកិច្ចស៊ើបសួរ លើកទីមួយ, កថាខណ្ឌទី១៤ ។

[80] សំណើសុំកិច្ចស៊ើបសួរ លើកទីមួយ, កថាខណ្ឌទី២០ ។

[81] សំណើសុំកិច្ចស៊ើបសួរ លើកទីពីរ, កថាខណ្ឌទី៤ ។

[82] សំណើសុំកិច្ចស៊ើបសួរ លើកទីបី, កថាខណ្ឌទី៧, ៩ ។

[83] សំណើសុំកិច្ចស៊ើបសួរ លើកទីបី, កថាខណ្ឌទី៣ ។

[84] សំណើសុំកិច្ចស៊ើបសួរ លើកទីបី, កថាខណ្ឌទី១៤, ១៦ ។

[85] សំណើសុំកិច្ចស៊ើបសួរ លើកទីមួយ, កថាខណ្ឌទី៥ ។

[86] សំណុំរឿងលេខ ០០២; សាលដីកាលើបណ្ដឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ១៥ កុម្ភៈ ២០១១, D427/3/15, ទំព័រទី៣២ ។

[87] សំណើសុំកិច្ចស៊ើបសួរ លើកទីមួយ, កថាខណ្ឌទី៨ ។

ស្នួរមួយដែលគាត់គិតថា ភាគច្រើនមិនទាន់ចប់សព្វគ្រប់ ។ ការដាក់ដីកាសន្និដ្ឋានស្ថាពរ ឬអាចជាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ មិនអាចជាឧបាស្រ័យសម្រាប់ដកហូតសិទ្ធិក្នុងការដាក់សំណើសុំបំពេញកិច្ចស៊ើបសួរទេដោយហេតុថា ដីកាសន្និដ្ឋានស្ថាពរ និងបណ្តឹងឧទ្ធរណ៍ ទំនងជានឹងមិនមានឥទ្ធិពលអ្វីឡើយទៅលើការប្រមូលភស្តុតាង ប៉ុន្តែវាគ្រាន់តែជាការវិភាគ និងការកំណត់ភស្តុតាងនៅពេលប្រមូលបានតែប៉ុណ្ណោះ ។

៧៤. ការបដិសេធលើសំណើសុំ ដោយសារតែបញ្ហាបច្ចេកទេស ស.ច.ស បានខកខានក្នុងការលើកស្ទួយចំពោះកាតព្វកិច្ចខាងផ្លូវច្បាប់របស់ខ្លួន អនុលោមតាម វិធាន ៥៥(១) និងបានជ្រៀតជ្រែកក្នុងគោលបំណងរបស់ អ.វ.ត.ក ដែលត្រូវនាំខ្លួនមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម មករកយុត្តិធម៌ និងលើកកម្ពស់ដល់ការផ្សះផ្សារជាតិ ។ បើយល់ស្របជាមួយ ស.ច.ស បានន័យថា អនុម័តយកគោលជំហរមួយដែលមិនអាចការពារខ្លួនបានផង និងទាំងមិនស៊ីសង្វាក់ទៅនឹងគោលការណ៍នានាដែលបញ្ជាក់អំពីការបង្កើតតុលាការនេះ និងការទទួលខុសត្រូវរបស់ ស.ច.ស ផង ។

## ៦. សេចក្តីសន្និដ្ឋាន

៧៥. ដូចមូលហេតុចែងពីខាងលើ សហព្រះរាជអាជ្ញាអន្តរជាតិ សូមស្នើដល់អង្គបុរេជំនុំជម្រះ ៖

(ក) សម្រេចថា ដីកាសម្រេចដែលកំពុងតវ៉ានេះ គ្មានសុពលភាព អាស្រ័យដោយមូលហេតុថា

(១) ស.ច.ស បានពឹងផ្អែកលើការបកស្រាយមិនត្រឹមត្រូវទៅលើច្បាប់ជាធរមាន ។

(២) ការខ្វែងយោបល់គ្នាពីដំបូង ដែលបានចុះកំណត់ហេតុទាក់ទងនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក្នុងសំណុំរឿងលេខ ០០៣ គ្រប់ដណ្តប់ទៅលើសកម្មភាពជាបន្តបន្ទាប់មកទៀត ។ ដូច្នេះមិនចាំបាច់មានកំណត់ហេតុថ្មីអំពីការខ្វែងយោបល់គ្នាទៀតទេ ។

(៣) តាមរបៀបផ្សេងវិញ ការបដិសេធចោលសំណើនានាដោយសារគ្មានសុពលភាព គឺ ស.ច.ស បានខកខានមិនបានយកចិត្តទុកដាក់ទៅលើគោលការណ៍ជាមូលដ្ឋាននានាដែលមានចែងនៅក្នុងវិធាន២១ និងបានបំពានកាតព្វកិច្ចខាងផ្លូវច្បាប់ ដើម្បីដឹកនាំកិច្ចស៊ើបសួរឱ្យបានចប់សព្វគ្រប់ និងដោយមិនលំអៀង ។

(ខ) បង្គាប់ឱ្យ ស.ច.ស ពិចារណាលើសំណើទាំងបួនរបស់សហព្រះរាជអាជ្ញាអន្តរជាតិ លើអង្គសេចក្តី ។

00712906



(គ) តាមស្មារតីនៃផលប្រយោជន៍សាធារណដ៏សំខាន់នៅក្នុងបញ្ហានេះ និងដើម្បីលើកកម្ពស់ទំនុកចិត្តរបស់សាធារណជនចំពោះការប្រព្រឹត្តទៅដោយប្រសិទ្ធិភាព និងឆាប់រហ័សរបស់តុលាការ៖

(i) អនុញ្ញាតឱ្យសហព្រះរាជអាជ្ញា ចេញច្បាប់នៃបណ្ដឹងឧទ្ធរណ៍ជាសាធារណៈ និងដែលបានលុបចេញផ្នែកខ្លះនេះ, និង

(ii) ធ្វើសេចក្ដីសម្រេចរបស់ខ្លួនលើបណ្ដឹងឧទ្ធរណ៍នេះ ជាសាធារណៈ ស្របទៅតាមទម្លាប់នៃការអនុវត្តរបស់អង្គបុរេជំនុំជម្រះដែលមានជារហូតមក ។

(ឃ) ពន្លឿនការពិចារណា និងការសម្រេចរបស់ខ្លួនឱ្យបានឆាប់ទៅលើបណ្ដឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងបញ្ហាស្នូលដ៏សំខាន់នេះ ចំពោះសុចរិតភាព និងកិត្តិនាមជាសាធារណៈរបស់ អ.វ.ត.ក, នីតិវិធីផ្ទៃក្នុងរបស់ កសព និង គ្រប់វិធានការផ្សេងៗទៅថ្ងៃខាងមុខ ដែលនឹងត្រូវចាត់ធ្វើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិចំពោះករណី ០០៣ និង ០០៤ ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១១ | លោក Andrew CAYLEY<br>សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | |